# ពាក្យប្រារព្ធ

សៀវភៅ សារីរិកធាតុបូជានិសំសោ អានិសង្សនៃការបូជាព្រះសារីរិកធាតុនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ រៀបរៀងឡើង ដោយយល់ឃើញថា ៖

ម្យ៉ាង គឺដើម្បីបាន ប្រគេន និងចែកជូនជាធម្មទាន នៅក្នុងឱកាសនៃពិធីបុណ្យវេរនូវបុស្បុកថ្មី ព្រះចេតិយថ្មី ជាដើម ថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ១៥ រោច ខែ វិសាខ ឆ្នាំ មមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៥ ឋិតនៅនាគេហដ្ឋានរបស់ឧបាសក **ង៉ៀប លេន** ឧបាសិកា **គឹម រីយ៉ា** ក្នុងខេត្តព្រះសីហនុ ។

ម្យ៉ាងទៀត កាលដែលពុទ្ធបរិស័ទ បានអាននូវសៀវភៅនេះហើយ គង់នឹងកើតនូវសេចក្តីជ្រះថ្លា ចំពោះរាល់សកម្មភាពនៃការគោរព ការបម្រើ និងការបូជាព្រះសារីរិកធាតុ របស់ពុទ្ធបរិស័ទ ក្នុងសម័យមុនៗដែលបានធ្វើ ហើយទីបំផុត អ្នកទាំងអស់នោះ សុទ្ធតែបានសម្រេចជាព្រះអរហន្ត...។

ប៉ុន្តែដោយពេលវេលា នៃការរៀបចំ ដើម្បីបោះពុម្ព

សៀវភៅនោះ កៀកកិតជិតថ្ងៃដែលត្រូវប្រារព្ធពិធីបុណ្យពេក ទើបមិនអាចចែកជូនតាមកាលកំណត់ ។ ឥឡូវបានសម្រេចហើយទាន! សូមនិមន្ត និងសូមអញ្ជើញរីករាយក្នុងការអាន ដើម្បីបានបុណ្យ និងបានបញ្ញាជាដើមចុះ ! បុណ្យឯណា ដែលខ្ញុំព្រះករុណា ខ្ញុំបាទ បានជាវនូវបុស្បុកថ្មី ព្រះចេតិយថ្មី ជាដើម ថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ និងការរៀបរៀងសៀវភៅ ចែកជាធម្មទាននេះផង ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រគេន និង សូមគោរពជូននូវបុណ្យកុសលនេះ ដល់ពុទ្ធបរិស័ទដែលបាន អាននូវសៀវភៅនេះទាំងអស់ សូមឲ្យបាននូវចំណែកបុណ្យ ស្មើៗគ្នា សូមអនុមោទនា ! សូមបុណ្យនេះ បានជាឧបនិស្ស័យ នៃការរួចផុតចាកទុក្ខ ដល់ព្រះនិព្វានកុំបីអាក់ខានឡើយ សូម អនុមោទនា ! សូមអនុមោទនាបុណ្យ !...។

ថ្ងៃ ១៤ រោច ខែ ជេស្ឋ ឆ្នាំ មមែ ពុទ្ធសករាជ ២៥៥៩

ខ្ញុំព្រះករុណា ខ្ញុំបាទ **ឃែត សុផាន់**

# សន្លឹកប្រាប់មាតិការ

ល.រ. ឈ្មោះអត្ថបទធម៌ ទំព័រ

១. ពាក្យប្រារព្ធ.......................................... ក
២. សន្លឹកប្រាប់មាតិការ.................................... គ
៣. រឿងប្រេតអ្នកពោលតិះដៀលការបូជាព្រះសារីរិកធាតុ............. ១
៤. **អានិសង្សនៃការបូជាព្រះសារី រិកធាតុ**
 ៤.១. រឿងព្រះបច្ចុបដ្ឋានសញ្ញកត្ថេរ..........................៧
 ៤.២. រឿងបីតវិមាន ........................................ ១១
 ៤.៣. រឿងព្រះនាគសមាលត្ថេរ ................................ ១៦
 ៤.៤. រឿងព្រះសបរិវារិយត្ថេរ ............................... ១៩
 ៤.៥. រឿងព្រះធាតុបូជកត្ថេរ ................................ ២២
 ៤.៦. រឿងព្រះថម្ភារោបកត្ថេរ ............................... ២៣
 ៤.៧. រឿងព្រះអតិឆត្តិយត្ថេរ ............................... ២៦
 ៤.៨. រឿងព្រះបទុមច្ឆទនិយត្ថេរ ............................ ២៩
 ៤.៩. រឿងព្រះបភង្ករត្ថេរ ................................. ៣២
 ៤.១០. រឿងចូឡរថវិមាន .................................... ៣៦
៥. ព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ ......................... ៥២
៦. ការចែកព្រះសារីរិកធាតុ ................................... ៥៦
៧. ការធ្វើនូវធាតុនិធាន ...................................... ៦៤
៨. សម័យកាលនៃព្រះបាទធម្មាសោក ............................... ៧០
៩. នាមពុទ្ធបរិស័ទដែលមានសទ្ធាបរិច្ចាគប្រាក់បោះពុម្ព.......... ៧៧

# រឿងប្រេតអ្នកពោលតិះដៀល
# ការបូជាព្រះសារីរិកធាតុ

(បិដកលេខ៥៦ ទំព័រ៨៨ និងអដ្ឋកថា )

កាលព្រះមានព្រះភាគ ស្តេចទ្រង់បរិនិព្វាន នៅចន្លោះដើមសាលព្រឹក្សទាំងគូក្នុងសាលវ័ន នៃពួកមល្លក្សត្រ ដែលជាទីឆៀងចូលទៅក្នុងក្រុងកុសិនារា ( ក្រោយមក ទោណព្រាហ្មណ៍) នឹងធ្វើការបែកព្រះធាតុ ។ ព្រះបាទអជាតសត្តុ បានទទួលចំណែកនៃព្រះធាតុចំនួន២នាឡិ បានកសាងព្រះស្តូប បញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធ នៅនាក្រុងរាជគ្រឹះ។

***សួរថា*** តើធ្វើយ៉ាងណា ?

***ឆ្លើយថា*** គឺព្រះរាជា បានដង្ហែតាំងតែអំពីក្រុងកុសិនារា រហូតដល់ក្រុងរាជគ្រឹះ ក្នុងចម្ងាយផ្លូវ២៥យោជន៍ ។ ក្នុងចន្លោះផ្លូវនោះ ទ្រង់បានឲ្យឈប់រវាងផ្លូវ៨ឧសភៈ(ម្តងៗ) ដើម្បីឲ្យមហាជនបានបូជា គ្រប់កន្លែងដែលបានឈប់នោះ ។ ដោយការនឹករលឹកដល់ព្រះពុទ្ធគុណ ទើបធ្វើការបូជា យ៉ាងឱឡារិកគគ្រឹកគគ្រេងឲ្យប្រព្រឹត្តទៅ រហូត៧ឆ្នាំ ៧ខែ ៧ថ្ងៃ ។ ពួកមនុស្សក្នុងទីនោះ រាប់ប្រមាណមិនបាន នាំគ្នាធ្វើចិត្តឲ្យជ្រះថ្លា

ក្នុងព្រះបរមសារីរិកធាតុ ក្រោយពីស្លាប់ បានចូលទៅកើតក្នុងឋានសួគ៌ ដោយអំណាចនៃការបូជាចំពោះព្រះសារីរិកធាតុ ។ ចំណែកពួកជនដែលជាមិច្ឆាទិដ្ឋិ មានចិត្តវិបល្លាស ព្រោះជាបុគ្គលមិនមានសទ្ធា ដោយការយល់ខុសរបស់ខ្លួន បាននាំគ្នាតិះដៀលថា **តាំងតែអំពីព្រះសមណគោតមបរិនិព្វានទៅ ពួកយើងរស់តែលេងនូវគ្រឿងប្រគំ ការងាររបស់ពួកយើងវិនាសអស់ហើយ** ក៏មានចិត្តប្រទូសរ៉ាយកើតឡើង សូម្បីក្នុងវត្ថុដែលគួរឲ្យកើតសេចក្តីជ្រះថ្លា បែរជាតិះដៀល ពួកជនមានប្រមាណ ៨៦០០០នាក់ ក្នុងទីនោះ បានទៅកើតក្នុងអបាយភូមិ (ដោយការតិះដៀលព្រះបរមធាតុ) ។ (ក្នុងកាលនោះ មាន) ភរិយា កូនស្រី និងកូនប្រសារស្រីរបស់កុដុម្ពិក:ម្នាក់ ដែលបរិបូណ៌ដោយទ្រព្យសម្បត្តិក្នុងក្រុងរាជគ្រឹះនោះឯង មានចិត្តជ្រះថ្លា នាំគ្នាគិតថា **ពួកយើងនឹងធ្វើការបូជាព្រះធាតុ** ទើបកាន់យកនូវសក្ការៈទាំងឡាយ មានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ប្រុងដើម្បីនឹងទៅកាន់ទីតម្កល់ព្រះធាតុ ។ កុដុម្ពិក:នោះគិតថា កឹ អដ្ឋិកានំ បូជនេន **ប្រយោជន៍អ្វីដោយការបូជាឆ្អឹងទាំងឡាយ (នោះ)** ទើបជេរពួកស្ត្រីទាំងនោះ ហើយពោលតិះដៀលចំពោះ

ការបូជាព្រះសារីរិកធាតុ ។ តែស្ត្រីទាំងនោះ មិនបានអើពើនិងពាក្យរបស់គាត់ទេ ក៏នាំគ្នាទៅក្នុងទីនោះ ធ្វើការបូជាព្រះសារីរិកធាតុហើយ ទើបត្រឡប់មកផ្ទះ មិនយូរប៉ុន្មាន ក៏ធ្វើមរណកាល ហើយទៅកើតក្នុងទេវលោក ។ ចំណែកកុដុម្ពិក:នោះ ត្រូវសេចក្ដីក្រោធគ្របសង្កត់ មិនយូរប៉ុន្មាន ស្លាប់ហើយ ទៅកើតក្នុងពួកប្រេត ព្រោះបាបកម្មនោះ ។

ក្រោយមក ថ្ងៃមួយ ព្រះមហាកស្សបៈមានអាយុ បានសម្ដែងនូវឥទ្ធាភិសង្ខារ(គឺសម្ដែងឫទ្ធិ) ដោយប្រការដែលពួកមនុស្សអាចឃើញប្រេតទាំងនោះ និងទេវតាទាំងនោះបាន លុះធ្វើយ៉ាងនេះហើយ ក៏ឈរត្រង់ទីលានព្រះចេតិយ សួរប្រេតអ្នកដែលពោលតិះដៀលព្រះសារីរិកធាតុនោះ ដោយគាថាទាំងនេះថា ៖

**អ្នកឋិតនៅឰដ៏អាកាស មានក្លិនអាក្រក់ស្អុយផ្សាយទៅ ឯពួកដង្កូវក៏នាំគ្នារុកស៊ីមាត់របស់អ្នកដែលមានក្លិនស្អុយ តើអ្នកបានធ្វើអំពើអ្វីក្នុងកាលមុន ?**

ព្រោះការផ្សាយទៅនៃក្លិនស្អុយ និងមាត់ដែលដង្កូវរុកស៊ីនោះ (បានជាពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម ) កាន់យក

គ្រឿងសស្ត្រា មកវះ(មាត់ដំបៅ)រឿយៗ ហើយស្រោចដោយទឹកខារ(ទឹកក្រូត) ថែមទៀត ។

អំពើអាក្រក់អ្វី ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត ? ព្រោះវិបាកនៃកម្មអ្វី អ្នកទើបបានទទួលសេចក្តីទុក្ខយ៉ាងនេះ ? ប្រេតនោះ ក៏បានទូលប្រាប់ដល់លោកថា ៖

បពិត្រលោកអ្នកនិរទុក្ខ (កាលមុន) ខ្ញុំជាឥស្សរៈ លើទ្រព្យ និងស្រូវអង្ករច្រើនណាស់ នៅក្នុងក្រុងរាជគ្រឹះ ដែលគួររីករាយ មានភ្នំឡោមព័ទ្ធជុំវិញ ។

(កាលពីជាតិមុន) ស្រីនេះជាភរិយារបស់ខ្ញុំ ស្រីនេះជាកូនស្រីរបស់ខ្ញុំ ស្រីនេះជាកូនប្រសាររបស់ខ្ញុំ ខ្ញុំបានហាមឃាត់ពួកគេ ដែលនាំគ្នាកាន់យកកម្រងផ្កា ផ្កាឧប្បល និងគ្រឿងលាបស្រលាបដែលមានតម្លៃ ទៅកាន់ព្រះស្តូប(ដើម្បីបូជាព្រះធាតុ) បាបកម្មនោះ គឺខ្ញុំបានធ្វើទុកហើយ ។

ពួកខ្ញុំមានចំនួន៨៦០០០នាក់ បានទទួលទុក្ខវេទនាចំពោះខ្លួន ដែលបានតិះដៀលនូវការបូជាព្រះស្តូបហើយ ទើបឆេះនៅក្នុងប្រេតវិស័យ ដែលដូចជានរក ព្រោះមានការលំបាកយ៉ាងខ្លាំង ។

នាកាលបុណ្យដង្ហែ ដែលគេបូជាឧទ្ទិសស្តូបនៃព្រះអរហន្តសម្មាសម្ពុទ្ធ កំពុងតែប្រព្រឹត្តទៅ ពួកជនណាប្រកាសទោសក្នុងការបូជាព្រះស្តូប(ដូចជាខ្ញុំ) ពួកជននោះ តែងវាកចេញចាកបុណ្យ(តែម្យ៉ាង) ។

លោកម្ចាស់ សូមទតមើល នូវពួកទេពអប្សរទាំងនេះ ដែលទ្រទ្រង់ផ្កាកម្រង តាក់តែងកាយ កំពុងតែហោះមក (តាមអាកាស) ទេពអប្សរទាំងនោះ ដែលបានសម្រេច (ដោយសម្បត្តិទិព្វ ) មានយសបរិវារ កំពុងតែសោយនូវផលនៃការបូជា (ព្រះសារីរិកធាតុ) ដោយកម្រងផ្កា ។

(បពិត្រលោកម្ចាស់កស្សបៈ) ពួកនាង ជាអ្នកមានបញ្ញា បានឃើញផលដ៏អស្ចារ្យ ដ៏ចំឡែក ដែលគួរព្រឺរោម (នៃបុណ្យដ៏តិចតួចនោះ) តែងធ្វើការនមស្ការ ពោលថា (នមោ នមោ) ចំពោះព្រះមហាមុនីអង្គនោះ ។

(លំដាប់នោះ) ប្រេតនោះមានចិត្តតក់ស្លុត កាលសម្តែងកម្មដែលខ្លួនគប្បីធ្វើតទៅ ទើបពោលថា ៖

សោហំ នូន ឥតោ គន្ត្វា, យោនឹ លទ្ធាន មានុសឹ,
ថូបបូជំ ករិស្សាមិ, អប្បមត្តោ បុនប្បុនំ ។

ខ្ញុំទៅអំពីបេតលោក(នេះ)ហើយ (បើ)បានកំណើតជាមនុស្ស ខ្ញុំនឹងជាអ្នកមិនប្រមាទ ហើយនឹងធ្វើការបូជាព្រះស្តូប (ដែលតម្កល់នូវព្រះសារីរិកធាតុ)រឿយៗដោយពិត ។

ព្រះមហាកស្សបៈ ដែលប្រេតពោលប្រាប់យ៉ាងនេះហើយ ទើបធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ សម្តែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាព្រមហើយ ។

ធាតុវិវណ្ណបេតវត្ថុ និងអដ្ឋកថាបរមត្ថទីបនី ចប់

**ពុទ្ធោ សោ ភគវា ពោធាយ ធម្មំ ទេសេតិ**

ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹង នូវអរិយសច្ចធម៌ទាំង៤ហើយ ទ្រង់សម្តែងធម៌ ដល់សត្វទាំងឡាយ ដើម្បីជាប្រយោជន៍ ដល់ការត្រាស់ដឹង នូវអរិយសច្ចធម៌ទាំង៤ផង ។

**ទន្តោ សោ ភគវា ទមថាយ ធម្មំ ទេសេតិ**

ព្រះមានព្រះភាគអង្គនោះ ទ្រង់ទូន្មាននូវឥន្ទ្រិយទាំង៦បានហើយ ទ្រង់សម្តែងធម៌ ដល់សត្វទាំងឡាយ ដើម្បីជាប្រយោជន៍ដល់ការទូន្មាន នូវឥន្ទ្រិយទាំង៦ផង ។

# អានិសង្សនៃការបូជាព្រះសារីរិកធាតុ

## ១. រឿងព្រះបច្ចុបដ្ឋានសញ្ញកត្ថេរ

(បិដកលេខ៧៣ ទំព័រ២៨ និងអដ្ឋកថា)

ព្រះបច្ចុបដ្ឋានសញ្ញកត្ថេរនេះ លោកធ្លាប់បានបំពេញកុសលមកហើយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃវិវដ្ដៈ ក្នុងកពមួយនោះ លោកបានកើតក្នុងកំណើតយក្ស ក្នុងកាលនៃព្រះ-មានព្រះភាគព្រះនាមអត្ថទស្សី កាលខាងក្រោយមក ព្រះអង្គក៏ទ្រង់បរិនិព្វានទៅ ព្រោះតែការមិនបានឃើញ ពេលដែលព្រះអង្គទ្រង់គង់ព្រះជន្មនៅ ទើបមានសេចក្ដីសោកស្ដាយយ៉ាងខ្លាំង ។ ក្នុងកាលនោះ អគ្គសាវករបស់ព្រះសម្មាសម្ពុទ្ធអត្ថទស្សី មាននាមថា **សាគរៈ** កាលទូន្មាន(យក្សនោះ) ទើបពោលថា **ការបូជាព្រះសារីរិកធាតុ របស់ព្រះមានព្រះភាគ រមែងមានផលច្រើន ដូចការបូជាដែលគេធ្វើហើយក្នុងកាលព្រះមានព្រះភាគទ្រង់គង់ព្រះជន្មនៅ ព្រោះអំណាចនៃចិត្តដែលជ្រះថ្លា (ហេតុដូច្នេះ) អ្នកចូរកសាងព្រះស្ដូបចុះ!** ។ យក្សបានស្ដាប់ហើយ កើតសេចក្ដីជ្រះថ្លា ទើបបបួលគ្នាកសាងស្តូប(ព្រះចេតិយ) រួចបញ្ចុះ

ព្រះបរមសារីរិកធាតុ និងបានបូជាព្រះស្តូបដែលតម្កល់ ព្រះ-សារីរិកធាតុនោះហើយ ចុតិអំពីកំណើតយក្ស បានសោយសម្បត្តិព្រះឥន្ទ្រក្នុងទេវលោក និងសម្បត្តិស្តេចចក្រពត្តិក្នុងមនុស្សលោក ។ ក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងត្រកូលដែលមានទ្រព្យច្រើនក្នុងនគរសាវត្ថី ដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនា បានចេញបួស មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយមក លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួន ក៏កើតសោមនស្ស កាលប្រកាសនូវអំពើនោះឲ្យប្រាកដច្បាស់ ដែលខ្លួនប្រព្រឹត្តហើយក្នុងកាលមុន ទើបពោលគាថាទាំងនេះថា ៖

**កាលព្រះសុគតព្រះនាមអត្ថទស្សី ទ្រង់បរិនិព្វានទៅ ខ្ញុំបានកើតក្នុងកំណើតយក្ស ក្នុងលំដាប់ស្មើគ្នា កាលនោះ ខ្ញុំបានដល់នូវយស ។**

(ខ្ញុំគិតថា) ឱហ្ន៎! យស ដែលអាត្មាអញបានហើយ មិនល្អសោះ ពន្លឺភ្លឺស្វាងក្នុងរាត្រីក៏មិនល្អ ការរះឡើងនៃព្រះអរុណក៏មិនល្អ ព្រោះថា កាលដែលភោគអាត្មាអញនៅមានព្រះសម្ពុទ្ធមានចក្ខុទ្រង់បរិនិព្វានទៅ ។

សាវកឈ្មោះ សាគរៈ បានដឹងច្បាស់ នូវតម្រិះរបស់ខ្ញុំ លោកមានប្រាជ្ញានឹងស្រង់ខ្ញុំឡើង ទើបនិមន្តមកកាន់សំណាក់ខ្ញុំ (ហើយប្រាប់ថា) នៃបុរសអ្នកមានប្រាជ្ញាល្អ អ្នកយំសោកធ្វើអ្វី អ្នកកុំខ្លាចឡើយ អ្នកចូរប្រព្រឹត្តធម៌ចុះ ការបរិបូណ៌ដោយពូជ គឺកុសលរបស់សត្វទាំងអស់ ព្រះពុទ្ធទ្រង់បានប្រគល់ឲ្យហើយ។ បុគ្គលណា បូជាព្រះសម្ពុទ្ធជាលោកនាយក ដែលទ្រង់គង់ព្រះជន្មនៅក្តី បូជាព្រះសារីរិកធាតុរបស់ព្រះជិនស្រី សូម្បីប៉ុនគ្រាប់ស្ពៃ ដែលទ្រង់បរិនិព្វានទៅហើយក្តី កាលបើចិត្តមានសេចក្តីជ្រះថ្លាស្មើ បុណ្យដែលដល់នូវភាពដ៏ធំ ក៏ស្មើគ្នា ព្រោះហេតុនោះ អ្នកចូរកសាងព្រះស្តូប ហើយបូជាព្រះជិនធាតុទាំងឡាយចុះ! ។

ខ្ញុំបានស្តាប់នូវព្រះវាចា នៃព្រះសាគរៈហើយ បានធ្វើពុទ្ធស្តូប (គឺព្រះចេតិយតម្កល់នូវព្រះសារីរិកធាតុ) ព្រមទាំង បានបម្រើព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធមុនីអស់៥ឆ្នាំ ។

បពិត្រព្រះអង្គជាធំជាងសត្វទ្វេបាទ ជាចម្បងក្នុងលោក ទ្រង់ប្រសើរបំផុតជាងនរជន ខ្ញុំបានសោយនូវសម្បត្តិ ហើយបានសម្រេចនូវព្រះអរហន្ត ព្រោះកុសលកម្មនោះ ។

ក្នុងកប្បទី៧០០ អំពីភទ្ទកប្បនេះទៅ ខ្ញុំបានជាស្តេចចក្រពត្តិ៤ដង មានប្រាជ្ញាក្រាស់ដូចផែនដី បរិបូណ៌ដោយរតនៈ៧

ប្រការ មានកម្លាំងច្រើន ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានឮមកថា ព្រះបច្ចុបដ្ឋានសញ្ញកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បច្ចុបដ្ឋានសញ្ញកត្ថេរាបទាន

និងអដ្ឋកថា ឈ្មោះវិសុទ្ធជនវិលាសិនី ចប់

**បុញ្ញទុក្ខិ បាបហានំ រតនត្តយវន្ទនា**
**សាបិ ទេតិ ឥដ្ឋបាកំ ន ច ទេតិ អនិដ្ឋកំ ។**

កិរិយានមស្ការថ្វាយបង្គំ នូវព្រះរតនត្រ័យ ជាគុណជាតិចម្រើនឡើងនៃបុណ្យ ជាគុណជាតិសូន្យទៅនៃបាប កិរិយានមស្ការថ្វាយបង្គំ នូវព្រះរតនត្រ័យនោះ តែងតែឲ្យផលជាទីប្រាថ្នា គឺមិនដែលឲ្យផល មិនជាទីប្រាថ្នាឡើយ ។

**សាធុ ពុទ្ធស្ស សុពោធិតា** ! ការត្រាស់ដឹងដ៏ប្រពៃនៃព្រះសម្មាសម្ពុទ្ធ ញុំាងប្រយោជន៍ឲ្យសម្រេច ដល់សត្វទាំងឡាយ ។

# ២. រឿងបីតវិមាន

(បិដកលេខ៥៥ ទំព័រ៩៩ និងអដ្ឋកថា )

បីតវិមាននោះ មានរឿងកើតឡើងដូចម្ដេច? (មានរឿងកើតឡើងថា) កាលព្រះមានព្រះភាគ ទ្រង់រលត់ខន្ធបរិនិព្វានទៅ ព្រះបាទអជាតសត្តុ ទ្រង់បានដង្ហែព្រះបរមសារីរិកធាតុដែលព្រះអង្គបានទទួលចំណែក(អំពីក្រុងកុសិនារា)មក ហើយបានកសាងព្រះស្តូប និងធ្វើបុណ្យឆ្លង ឧបាសិកានៅក្នុងក្រុងរាជគ្រឹះម្នាក់ មានកតសរីរបដិបដ្ឋនា (គឺមានការរៀបរយខ្លួនប្រាណបានត្រឹមត្រូវល្អ) តាំងអំពីព្រឹកជាស្រេច គិតថា **អញនឹងបូជាព្រះស្តូបរបស់ព្រះសាស្តា** ហើយកាន់ផ្កាននោងព្រៃ៤ទងតាមដែលខ្លួនបានមកហើយ មានចិត្តគឹកម្នាំងសទ្ធាលើកឡើងហើយ មិនបានគិតពិចារណាដល់អន្តរាយតាមផ្លូវ ដើរមានមុខ(គឺចិត្តគិត)ឆ្ពោះទៅកាន់ព្រះស្តូបតែប៉ុណ្ណោះដើរទៅ ។ ពេលនោះ មេគោមានកូនខ្ចី ក៏ស្ទុះរត់ទៅយ៉ាងលឿន ជល់គាត់រំធដោយស្នែង ធ្វើឲ្យដល់នូវការអស់ជីវិតទៅ ។ នាងក៏ទៅកើតក្នុងឋានសួគ៌ជាន់តាវត្តិង្ស ដោយហេតុនោះឯង កាលសក្កទេវរាជ ទ្រង់យាងទៅដើម្បីកីឡា(ការលេង)ក្នុងឧទ្យាន នាងមាន

ខ្លួនប្រាកដ ព្រមទាំងទេវរថ គ្របសង្កត់នូវទេពធីតាទាំងអស់ ដោយរស្មីនៃសរីរៈរបស់ខ្លួន ក្នុងកណ្ដាលនៃទេពអប្សរជាស្រី ប្រាំពីរកោដិកន្លះ ដែលជាបរិវារ ។ សក្កទេវរាជ ទ្រង់ទតឃើញ នាងទេពធីតាថ្មីនោះ ទើបមានព្រះទ័យស្ញើច ស្ញប់ស្ញែង កើត អស្ចារ្យបំផ្លែក(មិនធ្លាប់មាន) ទ្រង់មានព្រះតម្រិះថា **យី**! **ទេព-ធីតាអង្គនេះ មានទេវឫទ្ធិដ៏ធំមហិមា មានសភាពបែបនេះ ព្រោះកម្មដ៏ធំក្រៃលែងដូចម្ដេចហ្ន៎**! ? ដូច្នេះហើយ ត្រាស់សួរ ទេពធីតា នោះ ដោយគាថាទាំងនេះថា ៖

**ម្នាលនាងដ៏ចម្រើន (នាង)មានសំពត់លឿង មានទង់លឿង ស្អិតស្អាងដោយគ្រឿងអលង្ការលឿង មានអវយវៈលាបស្រលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មានប្រាសាទលឿង មានទីដេកលឿង មានឆត្រលឿង មានរថលឿង មានសេះលឿង មានវីជនី(ផ្លិត)លឿង នាងបានធ្វើអំពើដូចម្ដេចក្នុងកាលមុននៃភាពជាមនុស្ស ? ម្នាលនាងទេពធីតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ?**

នាងទេពធីតានោះ ទូលប្រាប់ដោយគាថាទាំងនេះថា ៖

**បពិត្រព្រះអង្គដ៏ចម្រើន វល្លិ៍នោងព្រៃ ជាជាតិវល្លិ៍ល្វីង**

ដែលគេមិនត្រូវការ ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំផ្កានោងព្រៃនោះ៤ទង ទៅបូជាព្រះស្តូប ឧទ្ទិសព្រះសារីរិកធាតុរបស់ព្រះសាស្តា ខ្ញុំម្ចាស់កំពុងតែមានចិត្តជ្រះថ្លា ប្រព្រឹត្តទៅក្នុងព្រះធាតុនោះ មិនបានក្រឡេកមើលផ្លូវជាទីមកនៃគោ គ្រានោះមេគោមកជល់ខ្ញុំម្ចាស់ ដែលមានចិត្ត(មនោរថ) មិនទាន់ដល់ព្រះស្តូបផង(ឲ្យស្លាប់ទៅ) តែបើខ្ញុំម្ចាស់បានសន្សំបុណ្យនោះ(សម្រេចតាមបំណង) ម្ទេះសមជាមានសម្បត្តិដ៏ច្រើន លើសលប់ជាងនេះទៅទៀត បពិត្រព្រះមឃវៈជាទេវកុញ្ជរ ខ្ញុំម្ចាស់បានលះបង់នូវរាងកាយជារបស់មនុស្សហើយ ទើបមកកើតជាមួយព្រះអង្គ ព្រោះកម្មនោះ ។

*គាថានេះ ជាពាក្យរបស់ពួកធម្មសង្គាហកាចារ្យថា ព្រះឥន្ទ្រនាម មឃវៈ ជាធំជាងពួកទេវតាក្នុងជាន់ត្រៃត្រិង្ស ទ្រង់ស្មើដោយដំរីកុញ្ជរ ក្នុងពួកទេវតា បានព្រះសណ្តាប់នូវពាក្យនោះហើយ កាលទ្រង់ញុំាងពួកទេវតាជាន់តាវត្តិង្សឲ្យជ្រះថ្លា ទើបបានត្រាស់ពាក្យនេះ នឹងមាតលីទេវបុត្ត ។*

*លំដាប់នោះ សក្កទេវរាជបានសម្តែងធម៌ដល់ពួកទេវតាមាន មាតលីទេវបុត្តជាប្រមុខ ដោយគាថាទាំងនេះថា ៖*

*ម្នាលមាតលី អ្នកចូរមើលនូវផលនៃកម្មដ៏វិចិត្រអស្ចារ្យនេះ ទេយ្យវត្ថុសូម្បីបន្តិចបន្តួច ដែលគេធ្វើហើយ ជាបុណ្យមានផលច្រើន ។*

*កាលបើចិត្តជ្រះថ្លាហើយ ក្នុងព្រះតថាគតសម្មាសម្ពុទ្ធក្តី ក្នុងសាវករបស់ព្រះអង្គក្តី ទក្ខិណា មិនឈ្មោះថាមានផលតិចតួចឡើយ ។*

**ម្នាលមាតលី អ្នកចូរមក យើងនឹងនាំគ្នាទៅបូជាព្រះសារីរិកធាតុរបស់ព្រះតថាគត ឲ្យក្រៃលែង ឲ្យអស្ចារ្យ ព្រោះថា ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។**

**ព្រះមានព្រះភាគទ្រង់ធរមាននៅក៏ដោយ បរិនិព្វានទៅហើយក៏ដោយ កាលបើចិត្តស្មើ ផលក៏ស្មើ ព្រោះថាសត្វទាំងឡាយ ទៅកាន់សុគតិ ដោយសារតែការតម្កល់ចិត្តឲ្យល្អជាហេតុ ។**

*ឱ ! ទាយកទាំងឡាយ តែងទៅកាន់ឋានសួគ៌បាន ព្រោះធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងឡាយនោះ ទ្រង់កើតឡើង ដើម្បីជាប្រយោជន៍ដល់ជនច្រើនហ្ន៎ ! ។*

*លុះសក្កៈជាធំជាងទេវតា ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបធ្វើការខ្វល់ខ្វាយ ការលេងក្នុងឧទ្យាន ឲ្យរម្ងាប់ចុះទៅ (គឺ*

ឈប់ទៅលេងក្នុងឧទ្យាន) យាងត្រឡប់ចេញអំពីឧទ្យាននោះវិញ ហើយទ្រង់ក៏ធ្វើការបូជាអស់៧ថ្ងៃ ក្នុងព្រះចូឡាមណី-ចេតិយ ជាស្ថានទីដែលព្រះអង្គទ្រង់បូជារឿយៗ ។ សម័យតមកព្រះអង្គបានប្រាប់រឿងនោះ ដល់ព្រះថេរៈនាមនារទៈ ដែលត្រាច់ចារិកទៅកាន់ទេវលោក ដោយគាថាទាំងនេះឯង ។ ព្រះថេរៈបានប្រាប់ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពួកលោក ទើបបានលើករឿងនោះឡើងកាន់សង្គាយនា ដោយប្រការដូច្នោះ ។

បរមត្ថទីបនី អដ្ឋកថា ពណ៌នាបីតវិមាន ចប់

**មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ**
**បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។**

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យ (ក៏)យ៉ាងនោះដែរ ។

## ៣. រឿងព្រះនាគសមាលត្ថេរ

*(បិដកលេខ៧២ ទំព័រ២៦៩ និងអដ្ឋកថា)*

*សូម្បីព្រះនាគសមាលត្ថេរនេះ ក៏បានបំពេញបុញ្ញសម្ភារមក ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំង-ឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពមួយនោះ បានកើតក្នុងផ្ទះមានត្រកូល ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមសិខី ពេលដែលព្រះសាស្តាទ្រង់គង់ព្រះជន្មនៅ ដឹងក្តីហើយនៅគ្រប់គ្រងផ្ទះ រវល់តែជាប់ជំពាក់ក្នុង(ការងារ) (មិនទាន់មានសេចក្តីជ្រះថ្លា) មិនបានធ្វើកម្មគឺ ការឃើញ ការឮ និងការបូជាចំពោះព្រះអង្គឡើយ តែកាលព្រះសាស្តាទ្រង់បរិនិព្វានហើយទើបញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះចេតិយ ដែលតម្កល់ព្រះសារីរិកធាតុនៃព្រះមានព្រះភាគអង្គនោះ ហើយបានបូជា***បាដលិបុប្ផា*** *(ផ្កាប្រទៀង) ញុំាងសោមនស្សឲ្យកើតឡើង រស់នៅរហូតអស់អាយុ ។ ដោយសោមនស្សនោះឯង លុះធ្វើកាលកិរិយាអំពីអត្តភាពនោះហើយ ទើបសោយសុខក្នុងទេវលោកទាំង៦ជាន់ក្រោយមក សោយសម្បត្តិមនុស្ស ក្នុងឋានមនុស្សទាំងឡាយក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងផ្ទះមានត្រកូលមួយ មានឈ្មោះ*

ហៅ ដែលមាតាបិតាដាក់ឲ្យថា **នាគសមាលៈ** ព្រោះមានសរីរៈដូចត្រួយដ៏ស្រទន់នៃដើមខ្ទឹម មានសេចក្តីជ្រះថ្លាក្នុងព្រះភគវាបួសហើយ មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយមក លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួន ហើយក៏កើតសោមនស្ស កាលនឹងប្រកាសនូវអំពើដែលខ្លួនបានប្រព្រឹត្តហើយក្នុងកាលមុននោះ ឲ្យប្រាកដច្បាស់ទើបពោលគាថាទាំងនេះថា ៖

ខ្ញុំបានរើសផ្កាប្រនៀង ដែលគេបោះចោលក្នុងផ្លូវធំ ដោយអើពើ ហើយលើកឡើងបូជា លើព្រះស្តូប(ដែលតម្កល់ព្រះសារីរិកធាតុ)នៃព្រះសិខី ជាផៅពង្សនៃលោក ។

ក្នុងកប្បទី៣១ រាប់អំពីភទ្ទកប្បនេះទៅ (ព្រោះហេតុតែ) ខ្ញុំបានធ្វើកម្មឯណាទុកហើយក្នុងកាលមុន ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការបូជាព្រះស្តូប ។

ក្នុងកប្បទី១៥ រាប់អំពីភទ្ទកប្បនេះទៅ ខ្ញុំបានជាស្តេចចក្រពត្តិឈ្មោះ បុប្ផិយៈ(ភូមិយៈ) បរិបូណ៌ដោយរតនៈ៧ប្រការមានកម្លាំងច្រើន ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់

ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា(សាសនារបស់ព្រះពុទ្ធ) ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮមកថា ព្រះនាគសមាលត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

នាគសមាលត្ថេរាបទាន និង អដ្ឋកថា

ឈ្មោះវិសុទ្ធជនវិលាសិនី ចប់

**សន្តោ សោ ភគវា សមថាយ ធម្មំ ទេសេតិ**

ព្រះមានព្រះភាគអង្គនោះ ទ្រង់ស្ងប់រំងាប់នូវកិលេសទាំងអស់ហើយ ទ្រង់សម្ដែងធម៌ ដល់សត្វទាំងឡាយ ដើម្បីជាប្រយោជន៍ ដល់ការស្ងប់រំងាប់នូវកិលេសទាំងអស់ផង ។

**តិណ្ណោ សោ ភគវា តរណាយ ធម្មំ ទេសេតិ**

ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្លងផុតនូវអន្លង់ទាំង ៤បានហើយ ទ្រង់សម្ដែងធម៌ ដល់សត្វទាំងឡាយ ដើម្បីជាប្រយោជន៍ ដល់ការឆ្លងផុតនូវអន្លង់ទាំង៤ផង ។

# ៤. រឿងព្រះសបរិវារិយត្ថេរ

(បិដកលេខ៧៣ ទំព័រ៦៨ និងអដ្ឋកថា)

សូម្បីព្រះសបរិវារិយត្ថេរនេះ ក៏ធ្លាប់បានធ្វើបុញ្ញាធិការមកហើយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងជាតិជាច្រើនអនេក ពេលមួយបានកើតក្នុងផ្ទះដែលមានត្រកូល ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ**បទុមុត្តរៈ** ដឹងក្តីហើយ ជាអ្នកមានទ្រព្យច្រើន មានភោគៈច្រើន ។ ក្រោយមក នាកាលព្រះមានព្រះភាគបទុមុត្តរៈបរិនិព្វានហើយ មហាជននាំគ្នាកសាងព្រះចេតិយយ៉ាងធំ តម្កល់ព្រះបរមធាតុរបស់ព្រះអង្គ ទុកគោរពបូជា ។ ក្នុងកាលនោះ ឧបាសកនេះ បានកសាងផ្ទះរក្សាព្រះចេតិយដោយឈើខ្លឹមចន្ទន៍ ទុកខាងលើព្រះចេតិយនោះ ហើយធ្វើការបូជាយ៉ាងធំក្រៃលែង ។ ដោយបុណ្យនោះឯង លោកទើបអន្ទោលទៅក្នុងទេវលោក និងមនុស្សលោក បានសោយសម្បត្តិក្នុងលោកទាំងពីរ ក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងផ្ទះដែលមានត្រកូលមួយ ចម្រើនវ័យហើយ ធ្វើកុសលកម្ម (តមក)បានបួសក្នុងព្រះពុទ្ធសាសនាដោយសទ្ធា មិនយូរប៉ុន្មាន ក៏បានជាព្រះ-

អរហន្ត ។ ក្នុងកាលជាខាងក្រោយមក លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួន ហើយកើតសោមនស្ស កាលប្រកាសនូវអំពើដែលខ្លួនប្រព្រឹត្តហើយក្នុងកាលមុននោះឲ្យប្រាកដច្បាស់ ទើបពោលគាថាទាំងនេះថា ៖

ព្រះជិនស្រីសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ជាចម្បងក្នុងលោក ជានរាសភៈ រុងរឿងដូចគំនរភ្លើង ទ្រង់បរិនិព្វានហើយ ។

កាលព្រះមហាវីរៈទ្រង់បរិនិព្វានហើយ ព្រះស្តូបដ៏ធំសម្បើម ក៏កើតមានឡើង (ក្នុងកាលនោះ)ពួកជនតែងនាំគ្នាចូលទៅបម្រើត្រង់ល្វែងតម្កល់ព្រះធាតុ ដ៏ប្រសើរឧត្តម ។

ខ្ញុំមានចិត្តរីករាយជ្រះថ្លា បានសាងវេទិកាខ្ចឹមចន្ទន៍ ក្នុងកាលនោះ ខ្ញុំបានថ្វាយធូបនិងគ្រឿងក្រអូប ដ៏សមគួរដល់ព្រះស្តូប(ព្រះចេតិយ) ។

កាលខ្ញុំកើតក្នុងភព(ណាៗ) ទោះបីជាទេវតា ឬមនុស្ស ខ្ញុំមិនដែលឃើញភាពថោកទាប(ទុគ៌ត)របស់ខ្ញុំឡើយ នេះជាផលនៃបុព្វកម្ម ។

ក្នុងកប្បទី១១៤ រាប់អំពីភទ្ទកប្បនេះទៅ ខ្ញុំបានជាស្តេចចក្រពត្តិ៨ដង មានឈ្មោះដូចគ្នាថា សមត្ថៈ ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះសបរិវារិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

សបរិវារិយត្ថេរាបទាន និងអដ្ឋកថា

ឈ្មោះវិសុទ្ធជនវិលាសិនី ចប់

**បរិនិព្វុតោ សោ ភគវា បរិនិព្វានាយ ធម្មំ ទេសេតិ** ព្រះមានព្រះភាគអង្គនោះ ទ្រង់រំលត់នូវកិលេសទាំងអស់បានហើយ ទ្រង់សម្ដែងធម៌ ដល់សត្វទាំងឡាយ ដើម្បីជាប្រយោជន៍ ដល់ការរំលត់នូវកិលេសទាំងអស់ផង ។

**សុខោ ពុទ្ធានមុប្បាទោ** កិរិយាត្រាស់ដឹងឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ ។

**ឥទម្បិ ពុទ្ធេ រតនំ បណីតំ** កែវគឺព្រះពុទ្ធនេះឯងជាកែវដ៏ឧត្ដម(ក្នុងលោក) ។

**អហោ ពុទ្ធោ** ! ឱហ្ន៎ ! ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ។

# ៥. រឿងព្រះធាតុបូជកត្ថេរ

( បិដកលេខ៧៣ ទំព័រ១៨៣ )

កាលព្រះលោកនាថ ព្រះនាមអត្ថទស្សី ជានរោត្តម ទ្រង់បរិនិព្វានទៅហើយ ខ្ញុំបានព្រះសារីរិកធាតុមួយព្រះអង្គ របស់ព្រះមានព្រះភាគ ទ្រង់ជាធំជាងសត្វជើងពីរ ជាតាទិបុគ្គល ។

ខ្ញុំបាននាំយកព្រះធាតុនោះ របស់ព្រះពុទ្ធទ្រង់មានផៅពង្សដ៏ខ្ពង់ខ្ពស់ដូចជាព្រះអាទិត្យ ហើយបានបម្រើអស់៥ឆ្នាំ ដូចកាលបម្រើព្រះអង្គជានរោត្តម ទ្រង់គង់ព្រះជន្មនៅឡើយ ។

ក្នុងកប្បទី៩៤ អំពីកទ្ទកប្បនេះទៅ (ព្រោះហេតុតែ) ខ្ញុំបានបូជាព្រះធាតុឯណាហើយ (ក្នុងកាលមុន) ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការបម្រើព្រះធាតុ ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានឮថា ព្រះធាតុបូជកត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ធាតុបូជកត្ថេរាបទាន ចប់

# ៦. រឿងព្រះថេរៈរោបកត្ថេរ

( បិដកលេខ៧៣ ទំព័រ៦៦ និងអដ្ឋកថា )

សូម្បីព្រះថេរៈរោបកត្ថេរ ក៏ធ្លាប់បានបំពេញកុសលមកហើយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងជាតិជាច្រើនអនេក ក្នុងភពមួយនោះ ក្នុងកាលនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមធម្មទស្សី បានកើតក្នុងផ្ទះដែលមានត្រកូលមួយ មានសទ្ធាជ្រះថ្លា កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ បានកសាងជង់ទង់ ចងទង់បង្ហូតឡើង ត្រង់ព្រះចេតិយដែលតម្កល់ព្រះបរមធាតុរបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ហើយបានឲ្យគេកសាងជណ្តើរ សម្រាប់ឡើងទៅកាន់ព្រះចេតិយដ៏ប្រសើរ និងបានយកកម្រងផ្កាម្ទិះជាច្រើន ឡើងតាមជណ្តើរទៅបូជា ។

លោករស់នៅរហូតដល់អស់អាយុ ធ្វើមរណៈហើយ បានអន្ទោលទៅក្នុងទេវលោកនិងមនុស្សលោក បានសោយសម្បត្តិក្នុងលោកទាំងពីរ គឺគេបូជាហើយក្នុងទីទាំងពួង ក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងផ្ទះដែលមានត្រកូលមួយ តាំងពីកុមារវ័យមក ជាអ្នកគួរដល់ការបូជា ជាអ្នកមានសទ្ធាជាប់ទាក់ទងនឹង

ព្រះសាសនា បានបួសហើយ (កាលព្យាយាម មិនយូរប៉ុន្មាន) ក៏បានសម្រេចជាព្រះអរហន្ត ព្រមទាំងបដិសម្ភិទា៤ (ក្នុងកាលជាខាងក្រោយមក) លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួន ហើយក៏កើតសោមនស្ស កាលប្រកាសនូវអំពើដែលខ្លួនប្រព្រឹត្តហើយក្នុងកាលមុនឲ្យប្រាកដច្បាស់ ទើបពោលគាថាទាំងនេះថា ៖

កាលព្រះលោកនាថ ព្រះនាមធម្មទស្សី ជានរាសភៈ ទ្រង់បរិនិព្វានហើយ ខ្ញុំបានលើកដង់ទង់ ត្រង់ព្រះចេតិយនៃព្រះពុទ្ធទ្រង់ប្រសើរបំផុតក្នុងលោក ។

ខ្ញុំបានឲ្យគេធ្វើជណ្ដើរ សម្រាប់ឡើងទៅកាន់ព្រះស្តូបដ៏ប្រសើរ ហើយបាននាំយកផ្កាម្ទិះឡើងទៅបូជាព្រះស្តូប ។

(ខ្ញុំមានចិត្តត្រេកអររីករាយ តែងតែបន្លឺឧទាន ដែលសម្រេចដោយបីតិដ៏មានកម្លាំងថា) **អហោ ពុទ្ធោ** ! ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ! **អហោ ធម្មោ** ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ! **អហោ នោ សត្ថុ សម្បទា** ! សម្បទារបស់ព្រះសាស្តាដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ! ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការបូជាព្រះស្តូប ។

ក្នុងកប្បទី៩៤ រាប់អំពីកប្បនេះទៅ ខ្ញុំបានជាស្ដេច

ចក្រពត្តិ១៦ដង មានឈ្មោះដូចគ្នាថា ចូបសីខៈ មានកម្លាំងច្រើន ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

*បានឮមកថា ព្រះថម្កាពោបកត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។*

*ថម្កាពោបកត្ថេរាបទាន និងអដ្ឋកថា*

*ឈ្មោះវិសុទ្ធជនវិលាសិនី ចប់*

**ពុទ្ធោតិ..., ធម្មោតិ...,**

**សង្ឃោតិ កិត្តិ យន្តស្ស ភាយេ ភវតិ យា បីតិ**

**វរមេវ ហិ សា បីតិ កសិណេនបិ ជម្ពុទីបស្ស ។**

*បីតិឯណា តែងកើតមានក្នុងកាយរបស់បុគ្គល អ្នកលាន់មាត់ថា* **ពុទ្ធោ, ធម្មោ, សង្ឃោ** *បីតិនោះ ប្រសើរជាង សម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ។*

*(សុមង្គលវិលាសិនី, បរមត្ថទីបនី និងដីកាទាំងឡាយ)*

# ៧. រឿងព្រះអតិឆត្តិយត្ថេរ

( បិដកលេខ៧៣ ទំព័រ៦៥ និងអដ្ឋកថា )

សូម្បីព្រះអតិឆត្តិយត្ថេរនេះ ក៏ធ្លាប់បានបំពេញកុសលមកហើយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងជាតិជាច្រើនអនេក ក្នុងកពមួយនោះ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអត្ថទស្សី បានកើតក្នុងផ្ទះដែលមានត្រកូលមួយ ព្រោះការមិនបានឃើញព្រះអង្គ ដែលទ្រង់គង់ព្រះជន្មនៅ ក្នុងកាលដែលព្រះអង្គបរិនិព្វានហើយ ទើបគិតថា ***ឱអាត្មាអញសាប-សូន្យហើយតើ!*** តែក៏ចេះធ្វើទុកក្នុងចិត្តថា ***អញនឹងធ្វើជាតិកំណើតរបស់អញឲ្យមានផល*** ហើយក៏បានឲ្យជាងធ្វើឆត្ររួតបូជាត្រង់ព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ របស់ព្រះ-មានព្រះភាគអង្គនោះ ក្នុងកាលតមក បានឲ្យជាងធ្វើឆត្រផ្កាបូជាត្រង់ព្រះចេតិយនោះទៀត ។ ដោយបុញ្ញកម្មនោះឯងលោកទើបអន្ទោលទៅ ក្នុងទេវលោក និងមនុស្សលោក បានទទួលសម្បត្តិក្នុងលោកទាំងពីរ ហើយក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងត្រកូលគហបតី ដឹងក្ដីហើយ មានសេចក្ដីជ្រះថ្លាក្នុង

ព្រះសាស្តា បួសហើយ បានរៀនយកនូវព្រះកម្មដ្ឋាន កាលព្យាយាម មិនយូរប៉ុន្មាន ក៏បានសម្រេចជាព្រះអរហន្ត ។

ក្នុងកាលជាខាងក្រោយមក លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួនហើយ ក៏កើតសោមនស្ស កាលនឹងប្រកាសនូវអំពើដែលខ្លួនប្រព្រឹត្តក្នុងកាលមុនឲ្យប្រាកដច្បាស់ ទើបពោលគាថាទាំងនេះថា ៖

កាលព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ទ្រង់ប្រសើរជាងនរជន ទ្រង់បរិនិព្វានទៅហើយ ខ្ញុំបានឲ្យគេធ្វើឆត្រូវត ហើយលើកឡើងត្រង់ព្រះស្តូប ។

ខ្ញុំបានមកនមស្ការព្រះលោកនាយក អស់កាលតាមកាល ហើយបានធ្វើគ្រឿងប្រក់ដោយផ្កា លើកឡើងធ្វើជាពិដាន ខាងលើឆត្រូវតទៀត ។

ក្នុងកប្បទី១១៧ រាប់អំពីកប្បនេះទៅ ខ្ញុំបានដល់នូវភាពជាស្តេចនៃទេវតា មិនដែលកើតជាមនុស្សម្តងណាឡើយ នេះជាផលនៃការបូជាព្រះស្តូប ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានពុំមកថា ព្រះអតិចត្តិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

អតិចត្តិយត្ថេរាបទាន និងអដ្ឋកថា

ឈ្មោះវិសុទ្ធជនវិលាសិនី ចប់

**ចិត្តីកតំ មហគ្ឃញ្ច អតុលំ ទុល្លភទស្សនំ**
**អនោមសត្តបរិភោគំ រតនំ តេន វុច្ចតិ ។**

វត្ថុ(ឯណា) ដែលសត្វលោក គួរធ្វើសេចក្ដីគោរព (កោតក្រែង បូជាដ៏ក្រៃលែង) ជាវត្ថុដែលមានតម្លៃច្រើន ជាវត្ថុដែលរកវត្ថុដទៃថ្លឹងស្មើគ្មាន ជាវត្ថុដែលពួកសត្វឃើញបានដោយកម្រក្នុងលោក ជាវត្ថុដែលសត្វអន់ទន់ទាប មិនអាចបរិភោគប្រើប្រាស់បាន ព្រោះហេតុដូច្នោះ វត្ថុនោះ ទើបហៅថា **រតនៈ** (គឺ **ព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ** និង **ព្រះសង្ឃរតនៈ** នេះឯង ) ។

## ៨. រឿងព្រះបទុមច្ឆទនិយត្ថេរ

(បិដកលេខ៧២ ទំព័រ២២២ និងអដ្ឋកថា)

សូម្បីព្រះបទុមច្ឆទនិយត្ថេរនេះ ក៏ធ្លាប់បានបំពេញបុញ្ញសម្ភារមក ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធអង្គមុនៗ ការសន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងជាតិជាច្រើនអនេក ក្នុងភពមួយនោះ បានកើតក្នុងផ្ទះមានត្រកូលមួយ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធវិបស្សី ដឹងក្តីហើយ ជ្រះថ្លាក្នុងព្រះរតនត្រ័យ កាលព្រះមានព្រះភាគវិបស្សីបរិនិព្វានហើយ លោកបានបូជាជើងថ្ករ ដោយផ្កាបទុម(ឈូកក្រហម) ទាំងឡាយ ដោយសេចក្តីជ្រះថ្លានៃចិត្តនោះឯង លោកតាំងនៅរហូតដល់អស់អាយុ ចុតិចាកអត្តភាពនោះ អន្ទោលទៅក្នុងសុគតិនោះឯង សោយសម្បត្តិទាំងពីរ គឺទិព្វសម្បត្តិ និងមនុស្សសម្បត្តិជាច្រើនដង ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយនេះ បានកើតក្នុងផ្ទះមានត្រកូលមួយ ដឹងក្តីហើយជ្រះថ្លាក្នុងព្រះសាស្តា បួសហើយ កាលព្យាយាមប្រឹងប្រែង មិនយូរប៉ុន្មាន ក៏បានជាព្រះអរហន្ត ។ កាលលោកសម្រាក ក្នុងទីនោះៗ មានទីពេលយប់ និងទីពេលថ្ងៃជាដើម វិហារមាន

ផ្កាបទុមទាំងឡាយបិទបាំងហើយ ។ ដោយហេតុនោះ លោកទើបប្រាកដនាមថា **បទុមច្ឆទនិយត្ថេរ** ។

ក្នុងកាលជាខាងក្រោយមក លោករលឹកឃើញនូវបុព្វកម្មរបស់ខ្លួនហើយ ក៏កើតសោមនស្ស កាលប្រកាសនូវអំពើដែលខ្លួនប្រព្រឹត្តហើយ ក្នុងកាលមុនឲ្យប្រាកដច្បាស់ ទើបពោលគាថាទាំងនេះថា ៖

*នាកាលព្រះលោកនាថ ជាអគ្គបុគ្គល ព្រះនាមវិបស្សី ទ្រង់បរិនិព្វានទៅហើយ ខ្ញុំយកផ្កាបទុម ដែលរីកស្រស់ល្អ លើកឡើងតម្កល់លើជើងថ្ករ ។*

*កាលជើងថ្ករដែលមហាជនលើកឡើងហើយ ក៏អណ្តែតត្រសែតទៅកាន់វេហាស៍នភាល័យ ខ្ញុំបានធ្វើនូវគ្រឿងបាំង ទុកព្ធដ៏អាកាស ហើយបាំងត្រង់ជើងថ្ករ(នោះ) ។*

*ក្នុងកប្បទី៩១ រាប់អំពីភទ្ទកប្បនេះទៅ (ព្រោះហេតុតែ) ខ្ញុំបានបូជាផ្កាឯណាទុកហើយ(ក្នុងកាលមុន) ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការបូជាព្រះពុទ្ធ ។*

*ក្នុងកប្បទី៤៧ រាប់អំពីភទ្ទកប្បនេះទៅ ខ្ញុំបានជាស្តេចចក្រពត្តិ មានឈ្មោះថា បទុមិស្សរៈ ជាអ្នកឈ្នះសង្គ្រាម មានទី*

បំផុតទល់នឹងមហាសមុទ្រទាំង៤ មានកម្លាំងច្រើន ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានឮមកថា ព្រះបទុមច្ឆទនិយត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បទុមច្ឆទនិយត្ថេរាបទាន និងអដ្ឋកថា

ឈ្មោះវិសុទ្ធជនវិលាសិនី ចប់

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ **ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្ដូប(ព្រះចេតិយ)ផង ព្រះបរមសារីរិកធាតុផង ព្រះធម៌៨ម៉ឺន៤ពាន់ព្រះធម្មក្ខន្ធ ដែលព្រះអង្គ ទ្រង់សម្ដែងហើយដោយប្រពៃផង** ជាវត្ថុ គឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុក ក្នុងឋានដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វទាំងឡាយ ។

# ៩. រឿងព្រះបតក្ខរត្ថេរ

( បិដកលេខ៧៤ ទំព័រ៥៣-៥៦ )

ព្រះចេតិយរបស់ព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ជាចម្បងក្នុងលោក ប្រកបដោយតាទិគុណ តាំងនៅក្នុងព្រៃធំ ជាទីកុះករដោយម្រឹគសាហាវ ។

បុគ្គលណាមួយ មិនអាច(ដើម្បី)នឹងទៅថ្វាយបង្គំ ព្រះ-ចេតិយបានឡើយ ព្រះចេតិយនោះ ត្រូវស្មៅនិងឈើវល្លិ៍រួបរឹតរលើងរលំ ។

កាលនោះ ខ្ញុំជាអ្នកធ្វើការងារក្នុងព្រៃ ជាមួយបិតា និងជីតា ក៏បានឃើញព្រះស្តូបក្នុងព្រៃធំ ដែលមានស្មៅវល្លិ៍រួបរឹតរលើងរលំនោះ ។

លុះខ្ញុំឃើញព្រះពុទ្ធស្តូបហើយ ក៏តាំងចិត្តគោរពថា ព្រះស្តូបរបស់ព្រះសម្ពុទ្ធដ៏ប្រសើរនេះ នៅក្នុងព្រៃ រលើងរលំខូចខាតអស់ អ្នកស្គាល់គុណនិងទោសនៃចេតិយនោះ បើមិនបានជម្រះនូវពុទ្ធស្តូប ដែលមិនកំបាំង ត្រឡប់ទៅប្រកបការងារដទៃវិញ ការណ៍នោះមិនសមគួរទេ ។

ទើបខ្ញុំជម្រះស្មៅនិងឈើវល្លិ៍ លើព្រះចេតិយ(នោះ)

ហើយថ្វាយបង្គំ រួចថយក្រោយអស់៨ជំហាន ទើបដើរចេញទៅ ។

លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្លួនសាងល្អនោះផង ដោយការតាំងចេតនានោះផង ។

វិមានរបស់ខ្ញុំ ដែលបុញ្ញកម្មតាក់តែងល្អហើយ ក្នុងឋាន-តាវត្តិង្សនោះ មានពណ៌ភ្លឺផ្លេកដូចមាស មានកំពស់ ៦០ យោជន៍ មានទំហំ៣០យោជន៍ ។

ខ្ញុំបានសោយទេវរាជ្យអស់៣០០ដង បានកើតជាស្ដេចចក្រពត្តិ២៥ដងទៀត ។

ខ្ញុំកាលអន្ទោលទៅ ក្នុងភពតូចនិងភពធំ រមែងបានភោគៈច្រើន ការខ្វះខាតដោយភោគៈ របស់ខ្ញុំមិនមានឡើយ នេះជាផលនៃការជម្រះ ។

កាលខ្ញុំទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬជិះលើ-កដំរី ខ្ញុំទៅកាន់ទិសណាៗ ព្រៃរមែងសម្រេចជាទីពឹង (របស់ខ្ញុំក្នុងទិសនោះៗ) ។

ខ្ញុំប្រកបហើយដោយបុញ្ញកម្ម មិនដែលឃើញដង្គត់ ឬ

បន្ទាដោយចក្ខុឡើយ ដង្គត់ជាដើមនោះ តែងចៀសចេញទៅឯងៗ ។

ខ្ញុំមិនដែលកើតរោគឃ្លង់ បូស ដំបៅ ស្រែង ឆ្កួតជ្រូក ឃ្លង់ដែក(កមរលាយ) ដំនួចពិស ឬកមរមាស់ឡើយ នេះជាផលនៃការជម្រះ ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំមិនដែលស្គាល់ពក ឬផ្លូច កើតក្នុងកាយរបស់ខ្ញុំទេ ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំតែងអន្ទោលទៅកើតក្នុងភពពីរ គឺទេវតា ឬមនុស្ស ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំមានសម្បុរដូចមាស មានរស្មីរុងរឿងក្នុងទីទាំងពួង ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ សេចក្ដីមិនគាប់ចិត្ត តែងប្រាសចេញទៅ សេចក្ដីគាប់ចិត្ត តែងប្រាកដឡើង ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ចិត្តរបស់ខ្ញុំស្អាតល្អ ជាចិត្តមានអារម្មណ៍តែមួយ ជាចិត្តតាំងនៅមាំល្អ ។

ខ្ញុំមានសេចក្ដីអស្ចារ្យដទៃទៀត គឺព្រោះតែពុទ្ធស្តូប ដែលខ្ញុំជម្រះនោះ ខ្ញុំអង្គុយលើអាសនៈតែមួយ ក៏បានសម្រេចនូវព្រះអរហត្ត ។

ក្នុងកប្បទីមួយសែន រាប់អំពីភទ្ទកប្បនេះទៅ កាលនោះព្រោះហេតុ ដែលខ្ញុំបានធ្វើកុសលកម្ម ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃការជម្រះ ។

បដិសម្ភិទា៤ វិមោក្ខ៨ និងអភិញ្ញា៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងព្រះពុទ្ធសាសនា ក៏ខ្ញុំបានប្រតិបត្តិហើយ ។

បានឮមកថា ព្រះបកង្គុរត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បកង្គុរត្ថេរាបទាន ចប់

# ១០. រឿងចូឡរថវិមាន

( បិដកលេខ៥៥ ទំព័រ១៣០ និងអដ្ឋកថា )

កាលព្រះមានព្រះភាគ ទ្រង់បរិនិព្វានហើយ ព្រះរាជា និងព្រាហ្មណ៍ទាំងឡាយ បានទទួលចំណែកព្រះធាតុ ហើយកសាងព្រះស្តូប(ព្រះចេតិយ) សម្រាប់តម្កល់នូវព្រះធាតុរបស់ព្រះសាស្តាទុកដើម្បីគោរពបូជាក្នុងទីនោះៗ នាកាលព្រះសាវកទាំងឡាយ ដែលបានជ្រើសរើស ដើម្បីនឹងធ្វើសង្គាយនាព្រះធម៌(បឋមសង្គាយនា) មានព្រះមហាកស្សបត្ថេរជាប្រធាន នៅក្នុងទីនោះៗ នឹងបរិស័ទរបស់ខ្លួនៗ ដោយឃើញដល់វេនេយ្យសត្វ ដរាបដល់ថ្ងៃចូលវស្សា ព្រះមហាកច្ចាយនៈ គង់នៅក្នុងព្រៃមួយកន្លែង(ជាយក្រុងរាជគ្រឹះ) ក្នុងបច្ចន្តប្រទេស ។ សម័យនោះ ព្រះរាជាព្រះនាម អស្សកៈ ទ្រង់គ្រប់គ្រងរាជ្យនៅក្នុងក្រុងបោតលិ ក្នុងដែនអស្សកៈ កុមារព្រះនាមថាសុជាត ជាបុត្តរបស់ព្រះជេដ្ឋទេពី នៃព្រះបាទអស្សកៈអង្គនោះ កាលមានព្រះជន្ម១៦ឆ្នាំ ត្រូវបិតានិរទេសចេញពីដែន ព្រោះចំណង់ក្នុងរាជ្យនៃព្រះកនិដ្ឋទេពី ទើបចូលទៅនៅព្រៃ អាស្រ័យនិងពួកព្រានព្រៃ ។

ដំណាលមកថា កុមារនោះ ធ្លាប់បានបួសក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធកស្សបៈ តាំងនៅក្នុងគុណ ត្រឹមតែសីលសុគតក្នុងភាពជាបុថុជ្ជន ហើយបានកើតក្នុងឋានសួគ៌ ជាន់តាវត្តិង្ស ឋិតនៅក្នុងទីនោះ ដរាបដល់អស់អាយុ វិលវល់តែក្នុងសុគតិនោះឯង ក្នុងពុទ្ធុប្បាទនេះ បានកើតក្នុងគភ៌នៃអគ្គមហេសីរបស់ព្រះបាទអស្សកៈ ក្នុងដែនអស្សកៈ មាននាមថា **សុជាត** ក្នុងកាលដែលព្រះមានព្រះភាគ ត្រាស់ដឹងបាន៣០ ព្រះវស្សាហើយ សុជាតកុមារ ជាអ្នកមានបរិវារច្រើន ។

កាលព្រះមាតារបស់សុជាតកុមារ ទ្រង់សោយវិលាល័យ (អស់ព្រះជន្ម)ទៅហើយនោះ ព្រះបាទអស្សកៈ បានតែងតាំងព្រះរាជទេវីមួយព្រះអង្គទៀត ទុកក្នុងតំណែងជាអគ្គមហេសីជំនួសព្រះមាតារបស់សុជាតកុមារ លុះក្រោយមក អគ្គមហេសីថ្មី បានប្រសូតិព្រះរាជឱរសមួយព្រះអង្គ ព្រះរាជាទតឃើញឱរសរបស់ព្រះនាងហើយ ក៏ទ្រង់ប្រោសប្រាណ បានប្រទានពរថា ម្នាលនាងដ៏ចម្រើន នាងចូរទទួលយកនូវពរ ដែលនាងប្រាថ្នាចុះ ។ ព្រះនាងធ្វើជាទទួលពរទុក (មិនទាន់ពោលសូមពរជាអ្វីឡើយ) លុះកាលសុជាតកុមារ មានព្រះជន្មបាន១៦ វស្សា

ទើបក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះអង្គទត ឃើញបុត្តរបស់ខ្ញុំម្ចាស់ហើយ បានព្រះរាជទានពរ ឥឡូវនេះ សូមព្រះអង្គ មេត្តាព្រះរាជទានពរនោះចុះ ។ ព្រះរាជាត្រាស់ថា នាងចូរទទួលយកពរចុះ ។ ព្រះនាងក្រាបទូលថា សូមព្រះអង្គ មេត្តាព្រះរាជទានរាជសម្បត្តិ ដល់បុត្តរបស់ខ្ញុំម្ចាស់ចុះ ។ ព្រះ-រាជាទ្រង់បដិសេធថា នែវសលី ស្រីថោកទាប កាលបើសុជាត កុមារ បុត្តរបស់អញ ដែលដូចជាទេវកុមារ កំពុងតែរស់នៅ ហេតុអ្វីនាងឯងពោលយ៉ាងនេះ ។ ព្រះទេវីកាលធ្វើបំណងនោះ រឿយៗ ក៏នៅតែមិនបានដូចព្រះទ័យ ថ្ងៃមួយ ព្រះនាងក្រាប ទូលថា បពិត្រព្រះសម្មតិទេព បើព្រះអង្គតាំងនៅក្នុងសច្ចៈ សូម ព្រះរាជទានពរដដែលនោះចុះ ព្រះរាជា ទ្រង់មានវិប្បដិសារៈ ដោយព្រះចិន្តាថា អញមិនបានពិចារណា ហើយឲ្យពរដល់ នាងនេះ ឯនាងនេះ ក៏នៅតែនិយាយយ៉ាងនេះ ទើបទ្រង់ត្រាស់ ហៅសុជាតកុមារមក ហើយត្រាស់ប្រាប់រឿងរ៉ាវនោះ ទាំងទឹក ព្រះនេត្រហូរស្រក់ទៅ ។ សុជាតកុមារឃើញព្រះបិតា ទ្រង់ សោកសៅ ដល់នូវការតូចព្រះទ័យ ទឹកព្រះនេត្រក៏ហូរស្រក់ទៅ ដែរ ហើយក្រាបទូលថា បពិត្រព្រះបិតា សូមទ្រង់អនុញ្ញាតចុះ

បុត្តនឹងទៅនៅក្នុងទីដទៃ ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យនេះហើយ ទើបត្រាស់ថា បិតានឹងឲ្យគេសាងក្រុងថ្មីដល់បុត្ត បុត្តគួរទៅនៅក្នុងក្រុងនោះចុះ សុជាតកុមារក៏មិនប្រាថ្នា ។ ព្រះ-រាជាត្រាស់ថា បិតានឹងបញ្ជូនបុត្ត ឲ្យទៅនៅក្នុងសំណាក់ព្រះ-រាជាជាសម្លាញ់របស់បិតា សុជាតកុមារ ក៏ទ្រង់មិនយល់ព្រម សូម្បីសំណូមពរនោះ ក្រាបទូលតែម្យ៉ាងថា បពិត្រព្រះបិតា បុត្តនឹងទៅនៅក្នុងព្រៃ ។ ព្រះរាជាឱបក្រសោបព្រះឱរស ជញ្ជាប់ត្រង់ព្រះសិរសា ហើយត្រាស់បណ្ដោយថា ដោយកាលកន្លងអស់ពីបិតាទៅ បុត្តចូរមកគ្រងរាជសម្បត្តិក្នុងនគរនេះចុះ ។

សុជាតកុមារនោះ កាលចូលទៅក្នុងព្រៃ អាស្រ័យនិងពួកព្រានព្រៃ ថ្ងៃមួយបានទៅដល់ព្រៃម្រឹគ ។ មានទេវបុត្តមួយអង្គធ្លាប់ជាសម្លាញ់ដ៏ប្រសើរ របស់សុជាតកុមារ ក្នុងកាលនៃព្រះ-អង្គនៅភាពជាសមណៈបានមកប្រលោមទ្រង់ ដោយរូបជាម្រឹគព្រោះការស្វែងរកប្រយោជន៍ថ្វាយ ទើបរត់ទៅដល់ទីជិតវសនដ្ឋាន របស់ព្រះមហាកច្ចាយនៈ ហើយក៏បាត់ទៅ ។ សុជាតកុមារកាលគិតថា អញនឹងចាប់ម្រឹគនេះ ក្នុងកាលឥឡូវនេះ ទើបរត់ស្ទុះចូលទៅដល់កន្ទែងរបស់ព្រះថេរៈ កាលមិនឃើញ

ម្រឹគ ឃើញតែព្រះថេរៈ គង់នៅត្រង់បណ្ណសាលា ទើបបាន ឈរប្រទត់ចុងធ្នូចុះក្នុងទីជិតលោក ។ ព្រះថេរៈ ក្រឡេកឃើញ សុជាតកុមារហើយ ជ្រាបរឿងដែលប្រព្រឹត្តទៅ របស់ទ្រង់ទាំង អស់ តាំងពីដំបូង តែកាលអនុគ្រោះ នឹងដើម្បីធ្វើការសង្គ្រោះ ព្រះថេរៈធ្វើហាក់ដូចជាមិនដឹងរឿង ហើយបានសាកសួរថា ៖

**អ្នកឈរប្រទត់ធ្នូយ៉ាងមាំ ដែលធ្វើអំពីឈើដ៏មានខ្លឹម អ្នក ជាខត្តិយរាជកុមារ ឬជាព្រានអ្នកដើរក្នុងព្រៃ ។**

លំដាប់នោះ សុជាតកុមារ កាលប្រកាសខ្លួន ទើបត្រាស់ ថា **បពិត្រលោកដ៏ចម្រើន ខ្ញុំជាកូនរបស់ស្តេចក្នុងដែនអស្សកៈ ជាអ្នកដើរក្នុងព្រៃ បពិត្រភិក្ខុ ខ្ញុំសូមប្រាប់ឈ្មោះរបស់ខ្ញុំដល់ លោក ពួកគេស្គាល់ខ្ញុំថា សុជាត ខ្ញុំកាលស្វែងរកម្រឹគ ទើប ធ្លាក់ចុះកាន់ព្រៃធំ តាមមកហើយ តែមិនឃើញម្រឹគ ខ្ញុំក៏បាន ឃើញលោកម្ចាស់ ហើយទើបបានឋិតនៅ ។**

ព្រះថេរៈបានស្តាប់ពាក្យនោះហើយ កាលធ្វើបដិសណ្ឋារ នឹងសុជាតកុមារនោះ ទើបទូលថា ៖

**បពិត្រព្រះអង្គទ្រង់មានបុណ្យច្រើន ទ្រង់មកល្អហើយ ទ្រង់មកមិនអាក្រក់ទេ ទ្រង់ទទួលទឹកចាកពីទីនេះ ហើយលាង**

ព្រះបាទទាំងពីររបស់ទ្រង់ចុះ នេះជាទឹកសោយដ៏ត្រជាក់ ដែលជងនាំមកអំពីជ្រោះភ្នំ បពិត្រព្រះរាជបុត្ត លុះទ្រង់សោយទឹកអំពីនោះហើយ សូមទ្រង់ចូលទៅគង់ លើកម្រាលដែលក្រាលហើយចុះ ។

*លំដាប់នោះ ព្រះរាជកុមារ កាលទទួលបដិសណ្ឋាររបស់ព្រះថេរៈ ទើបត្រាស់ថា*

បពិត្រព្រះមហាមុនី វាចារបស់លោកពីរោះណាស់ គួរឲ្យចង់ស្តាប់ ជាវាចាមិនមានទោស មានប្រយោជន៍ ជាវាចាត្រឹម-ត្រូវ ទាំងលោកម្ចាស់ ក៏ពោលពាក្យនាំមកនូវជាប្រយោជន៍ ដោយឧបាយនៃប្រាជ្ញា ។ បពិត្រឥសីនិសក: សេចក្តីត្រេកអរដូចម្តេចរបស់លោកកាលនៅក្នុងព្រៃ ខ្ញុំសួរហើយ សូមលោកប្រាប់ ខ្ញុំនឹងផ្ទៀងស្តាប់នូវគន្ធងពាក្យរបស់លោក ហើយប្រតិ-បត្តិតាមនូវចំណែកធម៌ ដែលនាំមកនូវប្រយោជន៍ ។

*ព្រះថេរៈកាលពោលនូវសម្មាបដិបត្តិ ដែលសមគួរដល់ព្រះរាជកុមារនោះ ទើបទូលថា*

បពិត្រព្រះរាជកុមារ ការមិនបៀតបៀនពួកសត្វទាំងពួងរមែងពេញចិត្តដល់យើង ការវៀរចាកកិរិយាលួចក្តី ការវៀរ

ចាកការប្រព្រឹត្តិ(ផិត)ក្បត់ក្ដី ការវៀរចាកការផឹកទឹកស្រវឹងក្ដី ការមិនត្រេកអរ(ក្នុងអកុសល)ក្ដី ការប្រព្រឹត្តិស្មើក្ដី ភាពជាអ្នកបេះដឹងច្រើនក្ដី ភាពជាអ្នកដឹងឧបការៈ ដែលគេធ្វើហើយក្ដី ធម៌ទាំងនុ៎ះ ជាធម៌គួរប្រាថ្នា ជាធម៌គួរសរសើរក្នុងបច្ចុប្បន្ន ។

ព្រះថេរៈពោលសម្មាបដិបត្តិយ៉ាងនេះហើយ កាលត្រួតមើលនូវអាយុសង្ខារ របស់ព្រះរាជកុមារនោះ ដោយអនាគតំ-សញ្ញាណ ក៏ឃើញថា ព្រះជន្មាយុនៅសល់ត្រឹមតែ៥ខែទៀតប៉ុណ្ណោះ ដូច្នេះដើម្បីឲ្យព្រះអង្គតក់ស្លុត ហើយតាំងនៅមាំក្នុងសម្មាបដិបត្តិនោះ ទើបពោលគាថានេះថា

បពិត្រព្រះរាជបុត្ត សេចក្ដីស្លាប់របស់ព្រះអង្គ មានក្នុងទីជិត ខាងអាយអំពី៥ខែ សូមព្រះអង្គទ្រង់ជ្រាប សូមព្រះអង្គទ្រង់ដោះខ្លួន (ឲ្យរួច)ចាកអបាយទុក្ខចុះ ។

លំដាប់នោះ សុជាតកុមារ កាលសួររកឧបាយនៃការរួចផុតពីសេចក្ដីស្លាប់ និងអបាយទុក្ខ ទើបត្រាស់ថា

ខ្ញុំនោះនឹងទៅកាន់ជនបទណា និងធ្វើអំពើដូចម្ដេច កិច្ចការដូចម្ដេចជាកិច្ចរបស់បុរស មួយទៀត ខ្ញុំត្រូវប្រកបដោយវិជ្ជាដូចម្ដេច ទើបជាអ្នកមិនចាស់ មិនស្លាប់ ។

លំដាប់នោះ ព្រះថេរៈដើម្បីសម្តែងធម៌ ដល់ព្រះរាជបុត្ត នោះ ទើបបានពោលគាថាទាំងនេះថា

**បពិត្រព្រះរាជបុត្ត ប្រទេសណាដែលសត្វទៅហើយ មិនចាស់ មិនស្លាប់ មិនមានទេ កិច្ចការ វិជ្ជា ជាកិច្ចរបស់បុរស ដែលសត្វធ្វើហើយ មិនចាស់ មិនស្លាប់នុ៎ះ មិនមានទេ ។ ទោះបីពួកក្សត្រ ដែលមានដែន មានទ្រព្យច្រើន មានភោគៈច្រើន មានទ្រព្យនិងធញ្ញាហារដ៏គ្រប់គ្រាន់ ពួកក្សត្រទាំងនោះ នឹងថា មិនចាស់ មិនស្លាប់ ក៏ទេ ។**

ទោះបីព្រះអង្គក៏ធ្លាប់បានឮហើយថា ពួកអន្ធកវេណ្ឌុបុត្ត ជាអ្នកក្លាហាន ខ្មីឃ្មាត ជាអ្នកអាចប្រហារនូវសត្រូវបាន ពួកអន្ធកវេណ្ឌុបុត្តទាំងនោះ ស្មើដោយសស្សតិវត្ថុ(វត្ថុដែលទៀងទាត់) ក៏គង់ដល់នូវការអស់ទៅនៃអាយុ វិនាសទៅអស់ហើយ ។

**ពួកជនទាំងនោះ គឺក្សត្រ ព្រាហ្មណ៍ វេស្សៈ(អ្នកជំនួញ) សូទ្រៈ(គូលី) ចណ្ឌាល និងបុក្កុសៈ(អ្នកចាក់សំរាម)ក្តី ពួកជនឯទៀតដែលមានជាតិក្រៅពីនេះក្តី ពួកជនទាំងនោះ មិនមែនមិនចាស់ មិនស្លាប់នុ៎ះទេ ។**

ពួកជនណា រាយមន្តប្រកបដោយអង្គ៦ ដែលពួកព្រហ្ម

បានគិតឃើញហើយក្តី ពួកជនឯទៀត ដែលមានវិជ្ជាក្តី សូម្បីពួកជនទាំងនោះ ក៏មិនមែនជាមិនចាស់ មិនស្លាប់ឡើយ ។

ម្យ៉ាងទៀត ទោះជាពួកឥសីណា ជាអ្នកស្ងប់រម្ងាប់ បានសង្រួមចិត្ត មានព្យាយាមដុតបំផ្លាញកិលេស ឥសីទាំងនោះ គ៏គង់លះបង់ចោលនូវសរីរៈ ទៅតាមកាលគួរ ។

សូម្បីព្រះអរហន្តទាំងឡាយ លោកមានចិត្តអប់រំហើយ បានធ្វើកិច្ចស្រេចហើយ ជាអ្នកមិនមានអាសវៈ ព្រោះអស់ទៅនៃបុណ្យនិងបាប ក៏គង់ដាក់ចុះនូវរាងកាយនេះដែរ ។

*សុជាតកុមារ កាលពោលដល់កម្មដែលខ្លួនគប្បីធ្វើ ទើបត្រាស់ថា*

បពិត្រព្រះមហាមុនី គាថាទាំងឡាយរបស់លោកម្ចាស់ ជាសុភាសិត មានប្រយោជន៍ ខ្ញុំកាលបើលោកពន្យល់ដោយសេចក្តីល្អហើយ (ឥឡូវនេះ) សូមលោកម្ចាស់ជាទីពឹង(សរណៈ) របស់ខ្ញុំផងចុះ ។

*លំដាប់នោះ ព្រះថេរៈកាលទូន្មានសុជាតកុមារនោះ ទើបបានពោលគាថានេះថា*

សូមទ្រង់កុំដល់នូវអាត្មាជាសរណៈឡើយ អាត្មាបានដល់

នូវព្រះពុទ្ធ ជាសក្យបុត្ត ដែលមានព្យាយាមធំណា ជាសរណៈ សូមព្រះអង្គ ទ្រង់ដល់នូវព្រះពុទ្ធនោះ ជាសរណៈចុះ ។

សុជាតកុមារត្រាស់យ៉ាងនេះថា

បពិត្រលោកអ្នកនិរទុក្ខ ព្រះពុទ្ធជាគ្រូរបស់លោកនោះ ទ្រង់គង់នៅក្នុងជនបទណា ខ្ញុំនឹងទៅកាន់ជនបទនោះ ដើម្បីឃើញព្រះអង្គ ទ្រង់ឈ្នះមារ មិនមានបុគ្គលប្រៀបផ្ទឹមបាន ។

ព្រះថេរៈទូលទៀតថា

ព្រះសាស្តាជាបុរសអាជានេយ្យ ទ្រង់សម្ភពក្នុងត្រកូលនៃព្រះបាទឱក្កាករាជ ក្នុងជនបទទិសខាងកើត តែថា(ឥឡូវនេះ) ព្រះអង្គទ្រង់បរិនិព្វានទៅហើយ ។

ព្រះរាជបុត្តនោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះថេរៈយ៉ាងនេះហើយ មានចិត្តជ្រះថ្លា ក៏តាំងនៅក្នុងសរណៈនិងសីល ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលថា

បពិត្រលោកអ្នកនិរទុក្ខ បើព្រះពុទ្ធជាសាស្តា របស់ពួកយើង ទ្រង់គង់នៅឡើយ ខ្ញុំព្រះករុណា គប្បីទៅអស់ទីមួយពាន់យោជន៍ ដើម្បីចូលទៅគាល់ព្រះអង្គ ។

បពិត្រលោកអ្នកនិរទុក្ខ បើទុកជាព្រះសាស្តា ទ្រង់បរិនិព្វានហើយក៏ដោយ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាព្រះមហាវីរៈ ដែលបរិនិព្វានហើយ ជាសរណៈ ។

ខ្ញុំសូមដល់នូវព្រះពុទ្ធជាសរណៈផង ខ្ញុំសូមដល់នូវព្រះធម៌ជាសរណៈផង ខ្ញុំសូមដល់នូវព្រះសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់មនុស្សនិងទេវតាជាសរណៈផង ។

ខ្ញុំសូមវៀរចាកបាណាតិបាតយ៉ាងដាច់ផង វៀរចាកអទិន្នាទានក្នុងលោកផង ជាអ្នកត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួនផង មិនពោលពាក្យកុហកផង មិនផឹកទឹកស្រវឹងផង ។

*កាលសុជាតកុមារ តាំងនៅក្នុងសរណគមន៍ និងសីល៥ហើយ ព្រះថេរៈក៏ទូលយ៉ាងនេះថា រាជកុមារ ប្រយោជន៍របស់ទ្រង់ដោយការនៅក្នុងព្រៃ ក្នុងទីនេះមិនមានទេ ទ្រង់នឹងអស់ព្រះជន្ម ព្រោះដូច្នោះ ទ្រង់គប្បីជាអ្នកទៅកាន់សំណាក់ព្រះរាជបិតារបស់ព្រះអង្គ ហើយធ្វើបុណ្យទាំងឡាយ មានការថ្វាយទាន ជាដើមចុះ នឹងជាអ្នកមានឋានសួគ៌ប្រព្រឹត្តទៅខាងមុខ ។ ដូច្នេះហើយ ទើបបែងចែក* **ព្រះបរមសារីរិកធាតុ** *ក្នុងសំណាក់របស់ខ្លួន ថ្វាយដល់ព្រះរាជកុមារ ។ ព្រះអង្គកាលមុន*

នឹងយាងទៅ ទើបត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណា នឹងចេញទៅពីទីនេះ តាមពាក្យរបស់លោក សូម្បីលោកម្ចាស់ ក៏គប្បីនិមន្តទៅក្នុងទីនោះផងទាន! ដើម្បីអនុគ្រោះដល់ខ្ញុំព្រះករុណា លុះជ្រាបនូវការទទួលនិមន្តរបស់ព្រះថេរៈហើយ ទើបថ្វាយបង្គំ ធ្វើប្រទក្សិណព្រះថេរៈ ហើយយាងទៅកាន់នគរព្រះបិតា ។ បានចូលទៅកាន់ឧទ្យាន ឲ្យគេក្រាបទូលព្រះរាជា ដើម្បីទ្រង់ជ្រាបនូវដំណើរដែលខ្លួនមកហើយ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ទ្រង់ព្រមដោយបរិវារ ស្តេចយាងចូលទៅកាន់ព្រះរាជឧទ្យាន កាលទ្រង់ជួបព្រះរាជឱរស ទ្រង់បានឱបក្រសោបបុត្តដោយការនឹករលឹករួចក៏បាននាំចូលទៅខាងក្នុងក្រុង ប្រាថ្នាដើម្បីនឹងអភិសេក ។ ព្រះរាជកុមារទូលថា បពិត្រព្រះបិតា បុត្តមានអាយុនៅតិចណាស់ តពីនេះទៅ ៤ខែទៀតប៉ុណ្ណោះ មរណៈនឹងមានប្រយោជន៍អ្វីដោយរាជសម្បត្តិដល់បុត្ត បុត្តសូមអាស្រ័យនិងព្រះបិតា ធ្វើបុណ្យតែម្យ៉ាងប៉ុណ្ណោះ ហើយក៏បានប្រកាសគុណរបស់ព្រះថេរៈ និងអានុភាពនៃព្រះរតនត្រ័យ ។ ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ទ្រង់ដល់នូវសេចក្តីតក់ស្លុត

និងមានព្រះទ័យជ្រះថ្លាចំពោះព្រះថេរៈ និងក្នុងព្រះរតនត្រ័យ បានឲ្យជាងកសាងវិហារដ៏ធំ ហើយទ្រង់បញ្ជូនទូត ទៅក្នុងសំណាក់ព្រះមហាកច្ចាយនត្ថេរ ។ សូម្បីព្រះថេរៈ កាលអនុគ្រោះព្រះរាជា និងមហាជន ក៏បាននិមន្តមក ។ ព្រះរាជាព្រមទាំងបរិវារ ចេញទៅទទួលព្រះថេរៈអំពីចម្ងាយតែម្តង ។ ហើយនិមន្តព្រះថេរៈឲ្យចូលកាន់វិហារ ទំនុកបម្រុងបច្ច័យបួនដោយគោរព ហើយតាំងនៅក្នុងត្រៃសរណៈគមន៍ និងសីល៥ ។ ចំណែកព្រះរាជកុមារ បានតាំងចិត្តសង្រួមក្នុងសីល ថែមទាំងបានធ្វើការទំនុកបម្រុង បម្រើព្រះថេរៈនិងភិក្ខុទាំងឡាយ ដោយគោរព ថ្វាយទាន ស្តាប់ព្រះធម៌ ដោយកាលកន្លងទៅ៤ខែ ក៏អស់ព្រះជន្ម ហើយបានទៅកើតក្នុងឋានតាវត្តិង្ស ។ វិមានខ្នាតបណ្តោយនិងទទឹង១០០យោជន៍ ប្រដាប់ដោយរតនៈ៧ប្រការ បានកើតឡើងហើយដោយបុញ្ញានុភាពនៃទេវបុត្តនោះ ទេវបុត្តនោះ មានទេពអប្សរមួយពាន់អង្គជាបរិវារ ។

ព្រះរាជា ទ្រង់បានធ្វើការរំលាយនូវសរីរៈរបស់ព្រះរាជ-បុត្ត ហើយបានញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ចំពោះភិក្ខុសង្ឃ និងធ្វើការបូជាព្រះចេតិយ មហាជនបានមកប្រជុំគ្នាក្នុងទីនោះ

សូម្បីព្រះថេរៈ ព្រមទាំងបរិវារ ក៏បានចូលទៅកាន់ទីនោះដែរ ។ គ្រានោះ ទេវបុត្តត្រួតមើលនូវកុសលកម្មដែលខ្លួនធ្វើហើយ គិតដោយភាពជាកតញ្ញូថា **អាត្មាអញ នឹងទៅថ្វាយបង្គំព្រះថេរៈ និងធ្វើគុណនៃព្រះសាសនាឲ្យប្រាកដឡើង** ទើបឡើងរថទិព្វមានរូបប្រាកដ ដែលគេឃើញបាន ព្រមទាំងបរិវារជាច្រើន មកប្រាកដចំពោះមុខព្រះមហាកច្ចាយនៈ ចុះអំពីរថទិព្វហើយ បានថ្វាយបង្គំទៀបជើងព្រះថេរៈ និងធ្វើបដិសណ្ឋារជាមួយព្រះបាទអស្សកៈ ដែលជាបិតា ហើយក៏ចូលទៅឈរផ្គងអញ្ជលី ឋិតនៅជិតព្រះថេរៈ ។ ព្រះថេរៈ បានសាកសួរទេវបុត្តនោះ ដោយគាថាទាំងនេះថា

ព្រះអាទិត្យមានរស្មីច្រើន មានពន្លឺធំបែបណា ចរទៅក្នុងអាកាស រមែងបំភ្លឺនូវទិសបាន យ៉ាងណា រថធំរបស់អ្នកនេះ ក៏មានប្រការបែបនោះដែរ រថជុំវិញខាងបណ្ដោយ (ឬទទឹង) មួយរយយោជន៍ ស្រោបជុំវិញដោយផែនមាស គល់ចន្ទោលវិចិត្រដោយកែវមុក្តា និងកែវមណី ក្បាច់ជាវិការនៃកែវពិទូរ្យ រំលេចព្ធង់ផែនមាសនិងប្រាក់ ញ៉ាំងរថឲ្យរុងរឿង ។

ចុងចន្ទោលរបស់រថសម្រេចដោយកែវពិទូរ្យ នឹមវិចិត្រ

ដោយកែវទទឹម ទាំងខ្សែក៏ប្រដាប់ដោយមាសនិងប្រាក់ សូម្បីសេះទាំងនេះ ក៏មានសន្ទុះទាន់ចិត្ត រមែងញុំាងរថឲ្យល្អ ។

អ្នកក៏ប្តុំប្តើងត្រដែតនៅក្នុងរថមាស មានពាហនៈទឹមដោយសេះមួយពាន់ ដូចជាព្រះឥន្ទ្រ ម្នាលទេវតាអ្នកមានយសអាត្មាសូមសួរ អ្នកជាបុគ្គលឈ្លាសវៃ តើយសដ៏ប្រសើរលើសលប់នេះ អ្នកបានមកដោយគុណអ្វី ?

ទេវបុត្តនោះ កាលត្រូវព្រះថេរៈសួរយ៉ាងនេះហើយ បានព្យាករណ៍ ដោយគាថាទាំងនេះថា

បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលមុន ខ្ញុំជាព្រះ-រាជបុត្ត ឈ្មោះសុជាត លោកម្ចាស់បានអនុគ្រោះដល់ខ្ញុំនោះ បានញុំាងខ្ញុំឲ្យតាំងនៅក្នុងសេចក្តីសង្រួម ។

លោកម្ចាស់បានដឹងនូវខ្ញុំ ថាអស់អាយុ ហើយក៏បានប្រទាន នូវ **ព្រះបរមសារីរិកធាតុ** របស់ព្រះសាស្តា ដល់ខ្ញុំ ។ លោកម្ចាស់បានប្រាប់ថា ម្នាលសុជាតរាជកុមារ **ព្រះអង្គចូរបូជា នូវព្រះសារីរិកធាតុនេះចុះ ការបូជានោះ នឹងបានជាប្រយោជន៍ដល់ព្រះអង្គ ។**

**ខ្ញុំក៏បានប្រឹងប្រែងបូជានូវព្រះសារីរិកធាតុនោះ** ដោយគ្រឿងក្រអូបនិងផ្កាកម្រងទាំងឡាយ លុះលះបង់នូវរាងកាយ

ជារបស់មនុស្សហើយ ទើបបានមកកើតក្នុងទីមនោរម្យដ៏ប្រសើរ គួរត្រេកត្រអាលពន់ពេក ដែលប្រកបដោយពួកទេវតាផ្សេង ៗ ជាដើម ខ្ញុំក៏ត្រេកអររីករាយ ដោយរបាំងនិងចម្រៀង ដែលមានទេពអប្សរចោមរោមត្រៀបត្រា ក្នុងឧទ្យាន ។

ទេវបុត្តទូលឆ្លើយសេចក្តី ដែលព្រះថេរៈសួរយ៉ាងនេះហើយ ក៏ថ្វាយបង្គំ ធ្វើប្រទក្សិណលាព្រះថេរៈ លាព្រះបិតាហើយឡើងរថត្រឡប់ទៅទេវលោកវិញ ។ សូម្បីព្រះថេរៈ ក៏បានធ្វើសេចក្តីនោះ ឲ្យជាអត្ថុប្បត្តិហេតុ(ហេតុការណ៍កើតឡើងនៃរឿង) សម្តែងធម្មកថាដោយពិស្តារ ដល់បរិស័ទដែលជួបជុំគ្នា ។ ធម្មកថានោះ បានជាប្រយោជន៍ដល់មហាជន ។ តពីនោះមកព្រះថេរៈ បានប្រាប់រឿងទាំងអស់នោះ ដល់ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ក្នុងកាលធ្វើបឋមសង្គាយនា តាមទំនងដែលខ្លួន និងទេវបុត្តនោះ បានពោលនោះឯង ឯព្រះធម្មសង្គាហកាចារ្យទាំងនោះ ក៏បានលើករឿងនោះ ឡើងកាន់សង្គាយនាដោយប្រការដូច្នេះឯង ។

បរមត្ថទីបនី អដ្ឋកថា

ពណ៌នាចូឡរថវិមាន ចប់

# ព្រះបរមសារីរិកធាតុ របស់ព្រះសម្មាសម្ពុទ្ធ

ក្នុងភទ្ទកប្បយើងនេះ មានព្រះសម្មាសម្ពុទ្ធត្រាស់ដឹង៥ព្រះអង្គ គឺ **ព្រះសម្មាសម្ពុទ្ធកក្កុសន្ធោ** ទ្រង់មានព្រះជន្ម៤ម៉ឺនឆ្នាំ **ព្រះសម្មាសម្ពុទ្ធកោនាគមនោ** ទ្រង់មានព្រះជន្ម៣ម៉ឺនឆ្នាំ **ព្រះ-សម្មាសម្ពុទ្ធកស្សបោ** ទ្រង់មានព្រះជន្ម២ម៉ឺនឆ្នាំ **ព្រះសម្មាសម្ពុទ្ធសមណគោតម**បរមគ្រូនៃយើង ទ្រង់មានព្រះជន្ម ត្រឹមតែ៨០ឆ្នាំប៉ុណ្ណោះ ដោយក្នុងកាលនោះ ជាសម័យដែលមនុស្សមានអាយុ១០០ឆ្នាំ ។ តទៅខាងមុខ ក្នុងភទ្ទកប្បនេះឯង នឹងមានព្រះសម្មាសម្ពុទ្ធត្រាស់ដឹងមួយព្រះអង្គទៀត គឺ **ព្រះសម្មាសម្ពុទ្ធមេត្តេយ្យោ(ព្រះអរិយមេត្រី)** ទ្រង់មានព្រះជន្ម៨ម៉ឺនឆ្នាំ ដោយក្នុងកាលនោះ ជាសម័យដែលមនុស្សមានអាយុ១០ម៉ឺនឆ្នាំ ។ ព្រះសម្មាសម្ពុទ្ធ ដែលមានព្រះជន្មវែងៗ ពេលបរិនិព្វានហើយ ព្រះសរីរៈរបស់ព្រះអង្គ មិនមានការបូជាឡើយ គឺពុទ្ធបរិស័ទបានកសាងព្រះចេតិយមាស ហើយតម្កល់នូវព្រះបរមសពនោះទាំងអស់ ទុកក្នុងទីមួយកន្លែង ។ ប៉ុន្តែ សម្រាប់ព្រះសម្មាសម្ពុទ្ធដែលមានព្រះជន្មខ្លី ដូចជា ព្រះសម្មាសម្ពុទ្ធសមណគោតមបរមគ្រូនៃយើងនេះ ក្រោយពេលព្រះអង្គបរិនិព្វាន មានការ

*បូជានូវព្រះបរមសពរបស់ព្រះអង្គ និងមានព្រះសារីរិកធាតុផ្សព្វផ្សាយទៅកាន់ទីកន្លែងផ្សេងៗ នេះក៏ព្រោះតែ មុនពេលបរិនិព្វាន ព្រះអង្គទ្រង់បានអធិដ្ឋាន ឲ្យព្រះធាតុបែកជាបំណែកតូចៗ ដូចមានសេចក្តីបញ្ជាក់ នៅក្នុងអដ្ឋកថាសុមង្គលវិលាសិនីថា ៖*

ភគវា បន អហំ ន ចិរំ ឋត្វា ឋត្វា បរិនិព្វាយាមិ មយ្ហំ សាសនំ ន តាវ សព្វត្ថ វិត្ថារិតំ តស្មា បរិនិព្វុតស្សបិ មេ សាសសមត្តម្បិ ធាតុំ គហេត្វា អត្តនោ អត្តនោ វសនដ្ឋានេ ចេតិយំ កត្វា បរិចរន្តោ មហាជនោ សគ្គបរាយនោ ហោតីតិ ធាតូនំ វិកិរណំ អធិដ្ឋាសិ ។

*កាលដែលព្រះមានព្រះភាគ ទ្រង់បានអធិដ្ឋានព្រះធាតុឲ្យជាបំណែកៗថា* ***តថាគតតាំងនៅមិនយូរឡើយ គង់តែបរិនិព្វាន ឯសាសនារបស់តថាគត ក៏មិនទាន់ផ្សព្វផ្សាយទៅកាន់ទីទាំងពួង ។ ព្រោះហេតុដូច្នោះ កាលតថាគត សូម្បីបរិនិព្វានហើយ មហាជន(ចូរ)បានកាន់យកនូវព្រះធាតុ សូម្បីមានខ្នាតប៉ុនគ្រាប់ស្ពៃ ហើយធ្វើព្រះចេតិយ ក្នុងទីកន្លែងរបស់ខ្លួនៗ (គោរព)ប្រតិបត្តិ(ចុះ) នឹងមានសុគតិជាទីប្រព្រឹត្តទៅខាងមុខ ។***

*ដូច្នេះ កាលដែលព្រះសរីរៈរបស់ព្រះមានព្រះភាគ ដែល*

ភ្លើងឆេះហើយ អាការណា ទោះព្រះឆវីក្តី ព្រះចម្មៈក្តី ព្រះមំសៈក្តី ព្រះន្ហារូក្តី ព្រះលសិកាក្តី អាការនោះ ក៏ឆេះអស់ដោយមិនមានផេះ និងកំញ៉មធ្យូងឡើយ នៅសល់តែព្រះសារីរិកធាតុសុទ្ធ ។

**កតិ បនស្ស ធាតុយោ វិប្បកិណ្ណា កតិ ន វិប្បកិណ្ណា។**

សួរថា ព្រះធាតុដូចម្តេច របស់ព្រះមានព្រះភាគ ដែលបែកជាបំណែក ព្រះធាតុដូចម្តេច ដែលមិនបែកជាបំណែក ?

នៅក្នុងគម្ពីរពុទ្ធវង្ស បិដកលេខ៧៧ ទំព័រ២៣៧ ត្រង់លេខយោង បានបញ្ជាក់ថា ៖

**ឧណ្ហិសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ**
**អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ ។**

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកជាបំណែក មាន៧អង្គ គឺ ព្រះឧណ្ហីសធាតុ(ឆ្អឹងថ្ងាស)១ ព្រះទាឋ-ធាតុ(ព្រះចង្កូមកែវ)៤ និងព្រះអក្ខកធាតុ(ឆ្អឹងដងកាំបិត)២ ព្រះ-សរីរិធាតុដ៏សេសក្រៅពីនោះ សុទ្ធតែបែកចេញ ជាបំណែកតូចៗ ។ (សូម្បីក្នុងព្រះធាតុ ដែលបែកជាបំណែកតូចៗទាំងនោះគឺ )

មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច នានា វណ្ណា ច ធាតុយោ ។

ព្រះធាតុខ្នាតធំ (មានទំហំ)ប៉ុនកំណាត់គ្រាប់សណ្ដែកបាយ ព្រះធាតុខ្នាតកណ្ដាល (មានទំហំ)ប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូច (មានទំហំ)ប៉ុនគ្រាប់ស្ពៃ មានពណ៌ផ្សេងៗ ។

មហន្តា សុវណ្ណវណ្ណា ច មុត្តវណ្ណា ច មជ្ឈិមា
ខុទ្ទកា មកុលវណ្ណា ច សោឡស ទោណមត្តិកា ។

ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្ដាល មានពណ៌ដូចកែវមុក្ដា និងព្រះធាតុខ្នាតតូច មានពណ៌ដូចផ្កាម្ទិះ រួមទាំងអស់ មានប្រមាណ១៦នាឡិ មានប្រមាណ១ទោណ ។

មហន្តា បញ្ច នាឡិយោ នាឡិយោ បញ្ច មជ្ឈិមា
ខុទ្ទកា ឆ នាឡី ចេវ ឯតា សព្វាបិ ធាតុយោ ។

ព្រះធាតុសូម្បីទាំងអស់ ព្រះធាតុខ្នាតធំ មាន(ចំនួន)៥នាឡិ ព្រះធាតុខ្នាតកណ្ដាល មាន(ចំនួន)៥នាឡិ និងព្រះធាតុខ្នាតតូច មាន(ចំនួន)៦នាឡិ ។ ...

ខ្ញុំសូមរៀបរាប់ដោយសង្ខេបតែប៉ុណ្ណោះចុះ ។

# ការចែកព្រះសារីរិកធាតុ

ក្នុងកាលនោះ ព្រះរាជាក្នុងដែនផ្សេងៗ មានព្រះបាទមាគធអជាតសត្តុ ជាដើម ទ្រង់បានឮដំណឹងថា ព្រះដ៏មាន-ព្រះភាគ ទ្រង់បរិនិព្វានហើយ ក្នុងក្រុងកុសិនារា ក៏បានបញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រ អ្នកក្រុងកុសិនារាថា ព្រះមានព្រះភាគជាក្សត្រ យើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសារីរិកធាតុ របស់ព្រះមានព្រះភាគដែរ យើងនឹងធ្វើព្រះស្តូបផង និង(ធ្វើ)ការបូជាផង ចំពោះព្រះសារីរិក-ធាតុនៃព្រះដ៏មានព្រះភាគ ។ តែពួកមល្លក្សត្រគិតថា ធម្មតាពុទ្ធរតនៈជាវត្ថុដ៏ប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោក ក៏រតនៈនេះ កើតក្នុងគាមក្ខេត្តរបស់យើង យើងមិនព្រមឲ្យអ្នកណាទេ ។

កាលបើពួកមល្លក្សត្រ មិនព្រមចែកព្រះសារីរិកធាតុយ៉ាងនេះ ព្រះរាជានិងព្រាហ្មណ៍ទាំងអស់នោះ ចាប់ផ្តើមនាំគ្នាធ្វើការច្បាំង ដើម្បីដណ្តើមយកព្រះសារីរិកធាតុ ។ ហើយក៏បានរៀបចំទ័ពរៀងៗខ្លួន ដើម្បីឡោមព័ទ្ធក្រុងកុសិនារា ។ ឯពួកមល្លក្សត្រក្រុងកុសិនារាវិញ ក៏រៀបចំកងទ័ព តតាំងច្បាំងវិញ

ដែរ ។ ក្នុងកាលនោះ ទោណព្រាហ្មណ៍ គាត់ជាអាចារ្យរបស់ក្សត្រ និងព្រាហ្មណ៍ទាំងនោះ ឃើញការវិវាទទាស់ទែងគ្នាដោយសារតែព្រះសារីរិកធាតុ (គាត់គិតថា) នេះជារឿងមិនសមទាល់តែសោះ ទើបឡើងទៅឈរលើកំពែងទីខ្ពស់ ស្រែកឡើងថា ៖

លោកទាំងឡាយដ៏ចម្រើន សូមស្តាប់ពាក្យខ្ញុំមួយម៉ាត់សិនព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជា**ខន្តិវាទ** (អ្នកពោលសរសើរនូវគុណនៃខន្តិមែនពិត) ការប្រហារគ្នា ការច្បាំងគ្នា ព្រោះតែចំណែកនៃព្រះសារីរិកធាតុ របស់ឧត្តមបុរសនេះ មិនប្រពៃឡើយ ។ បពិត្រលោកទាំងឡាយដ៏ចម្រើន យើងទាំងអស់គ្នាគួរតែស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកនូវព្រះសារីរិកធាតុ ឲ្យជា៨ចំណែក ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើន គង់ជ្រះថ្លាចំពោះព្រះសម្ពុទ្ធ មានចក្ខុមិនលែង ។

កាលទោណព្រាហ្មណ៍ ពោលពាក្យនេះលើកទី១ គ្មានអ្នកណាយកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះម្នាក់ៗគិតតែថា ត្រូវច្បាំងៗ ។ តែអាស្រ័យទោណព្រាហ្មណ៍ គាត់ជាអាចារ្យរបស់

ក្សត្រ និងព្រាហ្មណ៍ទូទាំងជម្ពូទ្វីប មិនមានក្សត្រនិងព្រាហ្មណ៍ណាមួយថាមិនស្គាល់ឡើយ ។ ទើបទោណព្រាហ្មណ៍ស្រែកប្រកាសយ៉ាងខ្លាំងៗជាពីរដងថា ៖

ពួកលោក ចាំសំឡេងអាចារ្យរបស់ខ្លួនមិនបានទេឬ ? ប្រសិនបើចាំបាន សូមស្ងាត់ស្ងៀមគ្រប់ៗគ្នា ហើយស្ដាប់វាចាដែលខ្ញុំពោល ។ ពួកក្សត្រទាំងនោះ បានឮសំឡេងស្រែកឡើងនោះ ក៏ចាំបានថា នេះជាសំឡេងរបស់ទោណព្រាហ្មណ៍ ជាអាចារ្យរបស់ខ្លួន ហើយក៏នាំគ្នាស្ងៀមស្ងាត់ទៅ ។ ទោណ-ព្រាហ្មណ៍ គាត់ក៏ប្រកាសឡើងដូចពាក្យមុននោះឯង ដើម្បីបបួលគ្នាចែកនូវព្រះសារីរិកធាតុ ឲ្យជា៨ចំណែក សម្រាប់ក្សត្រនិងព្រាហ្មណ៍៨នគរ ដែលមកជួបជុំគ្នានៅទីនោះ ។ ក្សត្រ និងព្រាហ្មណ៍ ក៏ព្រមតាមទោណព្រាហ្មណ៍ ហើយមានឆន្ទៈតែមួយថា នឹងចែកឲ្យបានស្មើៗគ្នា ។ ទោណព្រាហ្មណ៍ បានដឹងពីការព្រមព្រៀងគ្នារបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះហើយ ក៏បានបញ្ជាឲ្យបើកតុម្ពមាសឡើង ដើម្បីចែកព្រះសារីរិកធាតុ ។ ពេលនោះព្រះរាជាទាំងឡាយ បានឈរនៅជិតតុម្ពមាសនោះ ឃើញនូវព្រះសារីរិកធាតុ មានពណ៌ដូចមាស ក៏ខ្សឹកខ្សួលកន្ទក់-

កន្ទេញថា ព្រះដ៏មានព្រះភាគជាសព្វញ្ញូ ក្នុងកាលមុន យើង បានឃើញសរីរៈរបស់ព្រះអង្គ មានពណ៌ដូចមាស ដែល ប្រដាប់តាក់តែងហើយ ដោយមហាបុរិសលក្ខណៈ៣២ប្រការ ដែលមានឆព្វណ្ណរង្សី៦ប្រការ និងលម្អរុងរឿងទៅដោយអនុ-ព្យញ្ជនៈ៨០ ឥឡូវនេះទៅសល់តែព្រះធាតុមានពណ៌ដូចមាស ប៉ុណ្ណោះ ។ ឯទោណព្រាហ្មណ៍ ដឹងនូវសេចក្តីប្រមាទ របស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះហើយ ក៏ចាប់យក**ទក្ខិណទាឋ** គឺព្រះចង្កូមកែវខាងស្តាំ ដាក់ក្នុងចន្លោះឈ្នួតក្បាល ។ កាលបើ ក្សត្រនិងព្រាហ្មណ៍ទាំងនោះ បន្ទោបង់សេចក្តីសោកខ្សឹកខ្សួល ហើយ ក៏បាននាំគ្នាចែកនូវព្រះធាតុនោះ ជា៨ចំណែក គឺ៖

១. ព្រះបាទមាគធអជាតសត្តុវេទេហីបុត្ត បានទទួល ព្រះធាតុមួយចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប (ព្រះចេតិយ) ក្នុងក្រុងរាជគ្រឹះ ។

២. ពួកក្សត្រលិច្ឆវី បានទទួលព្រះធាតុមួយចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងក្រុងវេ-សាលី ។

៣. ពួកក្សត្រអ្នកក្រុងកបិលវត្ថុ បានទទួលព្រះធាតុមួយ

ចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងក្រុងកបិលវត្ថុ ។

៤. ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ បានទទួលព្រះធាតុមួយចំណែក គឺ២នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងក្រុងអល្លកប្បៈ ។

៥. ពួកក្សត្រកោឡិយៈ អ្នករាមគ្រាម បានទទួលព្រះធាតុមួយចំណែក គឺ២នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងរាមគ្រាម ។

៦. ព្រាហ្មណ៍អ្នកវេដ្ឋទីបកៈ បានទទួលព្រះធាតុមួយចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងដែនវេដ្ឋទីបកៈ ។

៧. ពួកមល្លក្សត្រអ្នកក្រុងបាវា បានទទួលព្រះធាតុមួយចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងក្រុងបាវា ។

៨. ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានទទួលព្រះធាតុមួយចំណែក គឺ២នាឡិ យកទៅបញ្ចុះក្នុងព្រះស្តូប(ព្រះចេតិយ) ក្នុងក្រុងកុសិនារា ។

ក្នុងពេលនោះ សក្កទេវរាជទ្រង់រមិលមើលថា អ្នកណា យកព្រះចង្កូមកែវខាងស្តាំទៅ? ក៏បានដឹងថា ទោណព្រាហ្មណ៍ ជាអ្នកយក ទុកក្នុងចន្លោះឈ្នួតក្បាល ក៏បានគិតថា ទោណ-ព្រាហ្មណ៍នេះ មិនអាចធ្វើសក្ការៈគោរពបូជា ចំពោះព្រះចង្កូម កែវនេះបានទេ ហើយក៏យកព្រះចង្កូមកែវពីទោណព្រាហ្មណ៍ នោះទៅ ។ ឯទោណព្រាហ្មណ៍ កាលចែកព្រះធាតុអស់ហើយ ក៏យកដៃចាប់មើលព្រះចង្កូមកែវ ត្រង់ឈ្នួតក្បាល មិនឃើញ តែមិនអាចសួរថា អ្នកណាយកព្រះចង្កូមកែវទៅ? ព្រោះខ្លួនជា ម្ចាស់ចំណែកហើយ ។ ទោណព្រាហ្មណ៍គិតថា បើដូច្នោះ អាត្មាអញនឹងសូមតុម្ពនេះ ជំនួសព្រះចង្កូមកែវវិញ ។ ទើប ពោលឡើងថា បពិត្រលោកដ៏ចម្រើន ខ្ញុំសូមតុម្ពនេះ ទៅបញ្ចុះ ក្នុងព្រះស្តូប គ្រាន់បានធ្វើសក្ការៈគោរពបូជា ។ ព្រះរាជា ទាំងឡាយ ក៏ព្រមអនុញ្ញាតឲ្យដល់ទោណព្រាហ្មណ៍នោះ ។ ចំណែកពួកក្សត្រមោរិយៈ អ្នកក្រុងបិប្ផលិវ័ន មកសូមព្រះធាតុ ក្រោយគេ មិនបាន ក៏សូមយកព្រះអង្គារគឺធ្យូង យកទៅធ្វើ ព្រះស្តូប(ព្រះចេតិយ) ដើម្បីធ្វើសក្ការៈបូជាក្នុងក្រុងរបស់ខ្លួន ។

ព្រះស្តូប(ព្រះចេតិយ) ដែលបញ្ចុះនូវព្រះសារីរិកធាតុ មាន

៨ បើរាប់តុម្ពចេតិយ១ផង ជា៩ បើគិតទាំងព្រះស្តូប ដែលបញ្ចុះព្រះអង្គារ១ទៀត ត្រូវជា១០ ដែលមហាជនបានកសាងទុកហើយ ក្នុងកាលនោះ ។

ក្នុងបិដកលេខ៧៧ ទំព័រ២៣៧ - ២៣៨ សម្តែងថា ៖

ព្រះចង្កូមកែវ១ (គឺព្រះចង្កូមកែវស្តាំខាងលើ ឋិតនៅ) ក្នុងឋានតាវត្តិង្ស ព្រះចង្កូមកែវ១ (គឺព្រះចង្កូមកែវស្តាំខាងក្រោមឋិត) នៅក្នុងកាលិង្គរាជ (សព្វថ្ងៃនៅប្រទេសសិរីលង្កា) ព្រះ-ចង្កូមកែវ១ (គឺព្រះចង្កូមកែវឆ្វេងខាងលើឋិតនៅ) ក្នុងដែនគន្ធារៈ (សព្វថ្ងៃនៅប្រទេសចិន) ព្រះចង្កូមកែវ១ (គឺព្រះចង្កូមកែវឆ្វេងខាងក្រោម) តម្កល់(នៅ)ក្នុងនាគបុរី(គឺពិភពនាគ) ។

ព្រះទន្ត(ធ្មេញ)ទាំង៤០គត់ ព្រះកេសា(សក់ទាំងឡាយ) និងព្រះលោមា(រោមទាំងឡាយ)ទាំងអស់ ពួកទេវតារៀងខ្លួនបាននាំទៅមួយៗ កាន់ចក្រវាឡដទៃៗ ។

បាត្រ ឈើច្រត់ និងចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកនៅក្នុងដែនវជីរ ស្បង់តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល គ្រឿងកម្រាល តម្កល់ទុកនៅក្នុងក្រុងឈ្មោះសិលៈ ។

ធម្មក្រក និងកាយពន្ធ(វត្ថពន្ធចង្កេះ) តម្កល់ទុកនៅក្នុង

ក្រុងបាតលីបុត្ត ឧទកសាដក តម្កល់ទុកនៅក្រុងចម្បា ព្រះឧណ្ណាលោម(រោមចិញ្ចើម) តម្កល់ទុកនៅក្នុងដែនកោសល ។

សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ឈ្នួត តម្កល់ទុកក្នុងឋានតាវត្តិង្ស ស្នាមព្រះបាទដ៏ប្រសើរដែលមិនបាត់ទៅ តម្កល់ទុកលើថ្ម សំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាល តម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាលនោះ ។

កាលនោះ ដែកភ្លើង តម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរនិងបំពង់ម្ជុល តម្កល់ទុកនៅក្នុងឥន្ទបត្តបុរី ។

កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ទុកក្នុងជនបទជាទីបំផុត ពួកមនុស្សតែងបូជា ចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីទ្រង់ប្រើប្រាស់ ។

ការផ្សាយទៅនៃព្រះធាតុ របស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបូរាណ(នៃព្រះពុទ្ធទាំងឡាយ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយ ជាខាងក្រោយ ។

# ការធ្វើនូវធាតុនិធាន

(ការកប់ព្រះសារីរិកធាតុទុកក្នុងដី)

អដ្ឋកថា សុមង្គលវិលាសិនី ទីឃនិកាយមហាបរិនិព្វាន សូត្រ លោកបានពន្យល់ថា កាលដែលព្រះមហាកស្សបត្ថេរ បានពិចារណា ឃើញការអន្តរាយនឹងកើតមានដល់ព្រះបរម-សារីរិកធាតុទាំងឡាយ ទើបចូលទៅរកព្រះបាទអជាតសត្តុ ទូលថា បពិត្រមហារាជ ព្រះបរមសារីរិកធាតុ គួរតែរក្សាទុក ដោយការធ្វើធាតុនិធាន គឺការកប់ទុកក្នុងដីដ៏សមគួរ ។ ព្រះបាទអជាតសត្តុ ត្រាស់ថា សាធុ!លោកម្ចាស់ កិច្ចដោយការធ្វើធាតុ-និធាន ជាកិច្ចរបស់ខ្ញុំព្រះករុណា តែខ្ញុំព្រះករុណា នឹងនាំព្រះ-បរមសារីរិកធាតុមកយ៉ាងណាទៅ ? ព្រះថេរៈឆ្លើយថា បពិត្រមហារាជ ការនាំព្រះធាតុ មិនមែនជាភារៈមហាបពិត្រទេ តែជាភារៈរបស់អាត្មា ។ ព្រះរាជា ត្រាស់ថា សាធុ!លោកម្ចាស់ សូមលោកម្ចាស់នាំព្រះធាតុមកចុះ ខ្ញុំព្រះករុណានឹងកប់ទុក ។ ព្រះថេរៈបាននាំព្រះធាតុដ៏សេស វៀរតែព្រះធាតុ ដែលរាជ-ត្រកូលចាត់ចែងទុក ចំណែកព្រះធាតុទាំងឡាយ ក្នុងរាមគ្រាម ពួកនាគបានរក្សាទុក ។ ព្រះថេរៈ ពិចារណាឃើញថា ការអន្ត-

រាយរបស់ព្រះធាតុទាំងនេះ រមែងមិនមាន ក្នុងកាលជាអនាគត ព្រះថេរៈទាំងឡាយ នឹងអារាធនាព្រះធាតុទាំងនេះ ទៅតម្កល់ទុកក្នុងមហាចេតិយ មហាវិហារ លង្កាទ្វីប (គឺក្នុងប្រទេសសិរី-លង្កាសព្វថ្ងៃ) ។ ព្រោះហេតុនោះ បានជាព្រះថេរៈមិនអារាធនាព្រះបរមធាតុទាំងនោះមក បានអារាធនាតែព្រះធាតុនៅក្នុងក្រុងទាំង៧ ទៅប្រតិស្ឋានទុកក្នុងទិសខាងកើត និងទិសខាងត្បូង(ទិសអាគ្នេយ៍)នៃក្រុងរាជគ្រឹះ (ព្រះថេរៈ)បានអធិដ្ឋានថា **ឥមស្មឹ ឋានេ យោ ចាសាណោ អត្ថិ សោ អន្តរធាយតុ បំសុ សុវិសុទ្ធា ហោតុ ឧទកំ មា ឧដ្ឋហតុ** ។ សិលាដែលមាននៅក្នុងទីនេះ ចូរអន្តរធានវិនាសទៅ ឲ្យនៅសល់តែដីសុទ្ធប៉ុណ្ណោះ ទឹកកុំផុសឡើងក្នុងទីនេះឡើយ ។

ចំណែកព្រះបាទអជាតសត្តុ ត្រាស់បញ្ជាឲ្យជីកដី ក្នុងស្ថានទីនោះ ដែលព្រះមហាកស្សបត្ថេរ បានអធិដ្ឋានរួចហើយ ទើបព្រះអង្គ ទ្រង់បញ្ជាឲ្យនាំដីដែលជីកឡើងមក ធ្វើជាឥដ្ឋ និងបានឲ្យសាងព្រះចេតិយថ្វាយព្រះអសីតិមហាសាវ័ក ។ ម្យ៉ាង-ទៀត អាចារ្យពួកខ្លះបានពោលថា ប្រសិនបើមានគេសួថា ព្រះ-រាជាឲ្យកសាងអ្វីនៅក្នុងទីនេះ ឆ្លើយថា ព្រះរាជាឲ្យកសាងព្រះ-

ចេតិយ ថ្វាយព្រះមហាសាវកទាំងឡាយ កាលពោលយ៉ាងនេះ បុគ្គលណាមួយ ក៏មិនបានដឹងថា ទីនេះកប់នូវព្រះធាតុ ។ ការដីកធ្វើធាតុនិធាននេះ មានជម្រៅ៨០ហត្ថ ព្រះរាជាបានបញ្ជាឲ្យក្រាលផ្ទៃបាតក្រោម ដោយលោហៈ ។ ព្រះបាទអជាតសត្តុទ្រង់បានបញ្ជាឲ្យធ្វើកូនកោដ្ឋ និងព្រះស្តូប បញ្ចុះព្រះបរមធាតុរបស់ព្រះមានព្រះភាគ ដោយវត្ថុផ្សេងៗ បានដល់ ១ ខ្លឹមចន្ទន៍-លឿង ២ ខ្លឹមចន្ទន៍ក្រហម ៣ ភ្លុក ៤ កែវ ៥ មាស ៦ ប្រាក់ ៧ កែវមណី ៨ កែវទទឹម ៩ កែវផ្ទេក ១០ កែវផលិក ដោយទ្រង់បញ្ជាឲ្យធ្វើវត្ថុនីមួយៗ ជាប្រអប់(កោដ្ឋ)៨ជាន់ និងស្តូប៨ជាន់ តាំងពីតូចរហូតដល់ធំ បំពាក់ត្រួតលើគ្នាជាជាន់ៗ បាន៨ជាន់ ដូចជា យកខ្លឹមចន្ទន៍លឿងធ្វើកោដ្ឋ៨ជាន់ និងធ្វើស្តូប៨ជាន់ជាដើម ។

ព្រះចេតិយកែវផលិក នៅជាន់លើបំផុត នៃព្រះចេតិយទាំងអស់ កាន់យកប្រមាណនៃព្រះចេតិយក្នុងថូបារាម ។ នៅពីខាងលើព្រះចេតិយកែវផលិកនោះ ព្រះរាជាទ្រង់បញ្ជាឲ្យកសាងផ្ទះកែវដែលសម្រេចដោយរតនៈ(កែវ៧ប្រការ) លើផ្ទះកែវនោះ ឲ្យកសាងផ្ទះដែលធ្វើដោយមាស ហើយនៅលើផ្ទះ

មាសនោះ ឲ្យកសាងផ្ទះដែលធ្វើដោយប្រាក់សុទ្ធ នៅលើផ្ទះប្រាក់នោះ ឲ្យកសាងផ្ទះធ្វើដោយមាសពណ៌ក្រហម(ស្ពាន់) លើផ្ទះ(ស្ពាន់)ពណ៌ក្រហមនោះ ទ្រង់បញ្ជាឲ្យរោយរាយដោយកម្ទេចខ្សាច់ដែលធ្វើដោយរតនៈទាំងពួង និងរោយដោយផ្កាឈើដែលកើតលើគោកនិងក្នុងទឹក មួយពាន់ផ្កា ព្រះរាជាបានឲ្យកសាងរូបព្រះបរមពោធិសត្វ (តាមជាតក)៥៥០ជាតិ រូបអសីតិមហាសាវ័ក រូបព្រះបាទសុទ្ធោទនមហារាជ រូបព្រះនាងសិរិមហាមាយា និងរូបសហជាតវត្ថុទាំង៧ (អ្វីៗ)ទាំងអស់ ដូចពោលមកនេះ គឺសុទ្ធតែធ្វើដោយមាស ។ ព្រះអង្គបានបញ្ជាឲ្យតាំងផ្ទាំងមាសដែលមានទឹកពេញ៥០០ ឲ្យដោតទង់មាស៥០០ ឲ្យតាំងប្រទីបមាស៥០០ ប្រទីបប្រាក់៥០០ ដោយប្រើទឹកក្រអូបជាប្រេង ប្រើសំពត់ទុកូលស្រ្តជាប្រឆេះភ្លើង បូជាព្រះបរមសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគ ។

គ្រានោះ ព្រះមហាកស្សបត្ថេរ បានអធិដ្ឋានថា មាលា មា មិលាយន្តុ គន្ធា មា វិនស្សន្តុ ទីបា មា វិជ្ឈាយន្តុ ភួងមាលា (កម្រងផ្កាឈើទាំងអស់នេះ) ចូរកុំស្វិតស្រពោន គ្រឿងក្រអូបចូរកុំវិនាស(នូវក្លិន) ដួងប្រទីបទាំងនេះ ចូរកុំរលត់ ។ ហើយបាន

ឲ្យគេចារឹកអក្សរចុះក្នុងផែនមាស ប្រតិស្ឋានក្នុងទីនោះថា អនាគតេ យទា អសោកោ នាម កុមារោ ឆត្តំ ឧស្សាបេត្វា អសោកោ នាម ធម្មរាជា ភវិស្សតិ សោ ឥមំ ធាតុយោ វិត្ថារិកា ករិស្សតិ ។ ក្នុងអនាគតកាល គ្រាអសោកកុមារ ញ៉ាំងគេឲ្យលើកនូវស្វេតច្ឆត្រឡើង ហើយនឹងបានជាអសោក ធម្មរាជា ព្រះរាជាអង្គនេះ ទ្រង់នឹងញ៉ាំងនូវព្រះបរមសារីរិក ធាតុទាំងនេះឲ្យផ្សព្វផ្សាយទៅ ។

ចំណែកព្រះបាទអជាតសត្តុ ទ្រង់នាំគ្រឿងប្រដាប់ទាំងអស់ចេញបូជា និងវេលាស្ដេចទ្រង់យាងចេញ អំពីទីកន្លែងបញ្ចុះព្រះបរមសារីរិកធាតុនោះ ព្រះអង្គបានបញ្ជាឲ្យបិទទ្វារផ្ទះព្រះបរមសារីរិកធាតុ និងឲ្យចាក់សោ ប្រថាប់ត្រាគ្រប់ៗជាន់រៀងដរាប រហូតដល់ផ្ទះដែលជាជាន់ខាងក្រៅបំផុត ព្រះអង្គបានចារឹកអក្សរទុកថា អនាគតេ ទលិទ្ទរាជា ឥមំ មណឹ គហេត្វា ធាតូនំ សក្ការំ ករោតុ ក្នុងកាលជាអនាគត ព្រះរាជាក្រខ្សត់ ចូរកាន់យកកែវមណីនេះ ហើយធ្វើសក្ការៈបូជាព្រះបរមសារីរិកធាតុទាំងឡាយនេះចុះ ! ។ ក្នុងកាលនោះ សក្កទេវរាជ ទ្រង់បានហៅវិស្សកម្មទេវបុត្តមក ហើយត្រាស់

បញ្ហាថា ម្នាលអ្នកដ៏ចម្រើន ព្រះបាទអជាតសត្តុ បានធ្វើធាតុនិធាន គឺការកប់ព្រះសារីរិកធាតុទុកហើយ អ្នកចូរនិម្មិត្តកងរក្សា ទុកក្នុងទីនោះ ។ វិស្សកម្មទេវបុត្ត បានមកហើយ ក៏ប្រកបនូវវាឡសង្ឃាដយន្ត រូបមនុស្សយន្តឈើ កាន់ព្រះខ័នពណ៌កែវផលិក មានលក្ខណៈគួរឲ្យខ្លាច វិលជុំវិញក្នុងបន្ទប់ព្រះសារីរិកធាតុនោះ យ៉ាងលឿនរហ័សដូចខ្យល់ព្យុះ ។ កាលវិស្សកម្មទេវបុត្តប្រកបគ្រឿងយន្តនោះហើយ បានចងគន្លឹះទុកភ្ជាប់ជាមួយនឹងផែនសិលា ដែលឡោមព័ទ្ធកំពែង ដូចជាផ្ទះដែលសាងដោយឥដ្ឋ ថែមទាំងបាននាំនូវផ្ទាំងថ្មធំ មកបិទទុកពីលើ រួចលុបដីពីខាងលើ និងធ្វើឲ្យរាបស្មើល្អ ។ កាលធ្វើនូវធាតុនិធាន(គឺការកប់នូវព្រះបរមសារីរិកធាតុ) សម្រេចយ៉ាងនេះហើយ ព្រះថេរៈ គង់ព្រះជន្មនៅ រហូតដល់អាយុកាលហើយ ក៏បរិនិព្វានទៅ សូម្បីព្រះរាជាក៏ទៅតាមយថាកម្ម ឯមនុស្សទាំងឡាយក្នុងកាលនោះ ក៏ធ្វើកាលកិរិយាអស់ទៅ ។

(ការធ្វើនូវធាតុនិធាន ចប់ )

# សម័យកាលនៃព្រះបាទធម្មាសោក

ក្នុងកាលជាចន្លោះខាងក្រោយមក គ្រាកាលអសោកកុមារ នៅជាអ្នកកាន់សាសនាព្រាហ្មណ៍ តាមរាជត្រកូលមក តែដោយអំណាចឧបនិស្ស័យនៃបុណ្យ ដែលបានសន្សំមក ជាមួយនឹងនិគ្រោធសាមណេរ ធ្វើឲ្យទ្រង់កើតសេចក្ដីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា បានជាព្រះរាជាព្រះនាមថា **អសោកមហារាជ** ទ្រង់បានទទួលនូវព្រះបរមសារីរិកធាតុ ពីទីដែលធ្វើជាតុនិធាននោះ ហើយបានធ្វើការផ្សព្វផ្សាយទៅក្នុងជម្ពូទ្វីប ។

តើព្រះអង្គឲ្យផ្សព្វផ្សាយទៅដូចម្ដេច ?

ព្រះបាទធម្មាសោក កើតសេចក្ដីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ក្រោយមក ព្រះអង្គមិនគិតពីការធ្វើសង្គ្រាមវាយយកទឹកដីទៀតទេ គឺព្រះអង្គទ្រង់ធ្វើសង្គ្រាមក្នុងផ្លូវព្រះធម៌ ដោយការបដិបត្តិតាមព្រះពុទ្ធសាសនា ។ មានថ្ងៃមួយនោះ ព្រះរាជា បានសាកសួរព្រះភិក្ខុសង្ឃថា ខ្ញុំព្រះករុណា បានធ្វើបុណ្យដ៏ធំធេង មានការថ្វាយទាន ជាដើម យ៉ាងនេះហើយ តើខ្ញុំព្រះករុណា បានឈ្មោះថា ជាទាយាទគឺជាញាតិរបស់ព្រះសាសនាដែរឬទេ? ព្រះមោគ្គលីបុត្តតិស្សត្ថេរតបថា បពិត្រមហារាជ ទ្រង់មិនទាន់

ជាញាតិរបស់ព្រះពុទ្ធសាសនានៅឡើយទេ **លុះត្រាតែ បុគ្គលណាមួយ ឲ្យកូនប្រុសក្តី កូនស្រីក្តីបួសក្នុងព្រះពុទ្ធសាសនា ទើបឈ្មោះថា ជាទាយាទគឺជាញាតិព្រះសាសនា** ។ ដោយសេចក្តីជ្រះថ្លាដ៏ខ្លាំងក្លាពេក ព្រះរាជាក៏ដាច់ចិត្តឲ្យព្រះរាជបុត្ត **មហិន្ទកុមារ** និងព្រះរាជបុត្រី ព្រះនាង**សង្ឃមិត្តា** បួសក្នុងព្រះពុទ្ធសាសនា គ្រាន់នឹងបានជាញាតិរបស់ព្រះពុទ្ធសាសនា ។ នៅក្នុងសម័យរបស់ព្រះរាជាអង្គនេះ ព្រះពុទ្ធសាសនាបានរុងរឿងខ្លាំងណាស់ រហូតទ្រង់អាចជម្រះនូវរឿងមន្ទិលក្នុងព្រះពុទ្ធសាសនា ដោយពួកអន្យតិរ្ថិយ មកបួសបួមក្នុងព្រះពុទ្ធសាសនា ហើយទ្រង់បានជា អគ្គពុទ្ធសាសនូបត្ថម្ភក្នុងការធ្វើតតិយសង្គាយនា ។ ចំណែកព្រះបរមសារីរិកធាតុ ដែលបាត់ឈឹងពីក្នុងលោកនេះ ក៏ត្រូវបានព្រះរាជាអង្គនេះ នាំយកមកផ្សព្វផ្សាយទូទៅក្នុងជម្ពូទ្វីបឡើងវិញ មានសម្តែងនៅក្នុងគម្ពីរសមន្តប្បាសាទិកាអដ្ឋកថាព្រះវិន័យ គម្ពីរសុមង្គលវិលាសិនីជាដើមថា ៖

ព្រះបាទធម្មាសោក ឲ្យជាងកសាងមហាវិហារ ឈ្មោះ **អសោការាម**ហើយ ទ្រង់បានតាំងកត្តដើម្បីថ្វាយព្រះភិក្ខុសង្ឃ៦សែនអង្គ និងទ្រង់បានឲ្យកសាងវិហារ៨៤០០០ខ្នង ដែល

ប្រដាប់ដោយព្រះចេតិយ៨៤០០០ព្រះចេតិយ ក្នុងជម្ពូទ្វីបទាំងអស់ ដោយសេចក្ដីជ្រះថ្លាក្នុងព្រះធម៌ ។ ក្រោយពីកសាងព្រះចេតិយរួច ព្រះរាជាបានបញ្ជារាជបុរស ឲ្យទៅរុះរើព្រះ-ចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុទាំង៨កន្លែង មានក្រុងរាជគ្រឹះ ជាដើម ក៏មិនបានឃើញព្រះសារីរិកធាតុតិចតួចឡើយ ព្រះអង្គបានបញ្ជា ឲ្យធ្វើព្រះចេតិយទាំងនោះ ដូចប្រក្រតីដើមវិញ ទើបព្រះរាជាចូលទៅក្រាបទូលដល់ព្រះសង្ឃត្ថេរ ឲ្យប្រជុំភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ដើម្បីសួរមើល ក្រែងមានព្រះថេរៈអង្គណា ជ្រាបរឿងព្រះធាតុនេះ ។ កាលបើជួបជុំព្រះភិក្ខុសង្ឃហើយ ព្រះរាជាត្រាស់សួរថា ខ្ញុំព្រះករុណា បានកសាងព្រះចេតិយរួចហើយ តែខ្ញុំព្រះករុណា រកព្រះបរមសារីរិកធាតុមិនបានសោះ តើលោកម្ចាស់អង្គណាធ្លាប់បានជួប ឃើញ ឬបានដឹងដំណឹង ពីព្រះបរមសារីរិកធាតុទេទាន ? ខណៈនោះមានព្រះថេរៈមួយព្រះអង្គ បួសតាំងពីព្រះជន្ម៧ឆ្នាំ រហូតមានអាយុ១២០ឆ្នាំ មានព្រះថេរៈវាចាតបថា បពិត្រមហារាជ កាលដែលអាត្មានៅជាសាមណេរតូច មានអាយុ៧ឆ្នាំ ព្រះមហាថេរៈជាបិតាអាត្មា បបួលអាត្មាថា នែសាមណេរ អ្នកចូរមកនេះ

ចូរយកផ្កាកម្រង និងគ្រឿងក្រអូប បូជាត្រង់កន្លែងនេះ ទីនេះតម្កល់ព្រះបរមសារីរិកធាតុ មហាបពិត្រ ទីកន្លែងនោះទេដឹងដែលតម្កល់ព្រះសារីរិកធាតុ ! ។ ព្រះរាជាទ្រង់ត្រេកអរជាខ្លាំងបានត្រាស់បញ្ជា ឲ្យជីកកកាយត្រង់កំពូលព្រះស្តូប ហើយបាននាំនូវស្តូបថ្ម និងផង់ធូលីចេញ ព្រះរាជាបានឃើញផែនថ្មខាងក្រោមហើយ បានឲ្យទម្លាយផ្ទាំងកំបោរ និងផ្ទាំងឥដ្ឋ ជុំវិញបរិវេណនោះ ព្រះបាទធម្មាសោក បានទតឃើញគ្រាប់ខ្សាច់រតនៈ ៧ប្រការ ដែលបានពោយរាយក្នុងបរិវេណនោះតាមលំដាប់ និងរាឡសង្ឃដយន្ត រូបមនុស្សយន្តឈើ កាន់ព្រះខ័ន រត់វិលជុំវិញយ៉ាងលឿនដូចជាខ្យល់ព្យុះ ព្រះរាជាបានបួងសួង សូមឲ្យសរសៃខ្សែទាំងពួងវិនាសទៅ សូម្បីធ្វើយ៉ាងនេះ ក៏មិនបានបាត់ឡើយ ព្រះអង្គនមស្ការទេវតាទាំងឡាយ ហើយត្រាស់ថា ខ្ញុំព្រះអង្គមកនេះ ដើម្បីអារាធនានូវព្រះធាតុ ទៅបញ្ចុះក្នុងព្រះ-ចេតិយទាំង៨៤០០០ ហើយព្រះអង្គធ្វើសក្ការដល់ពពួកទេវតាកុំឲ្យធ្វើអន្តរាយដល់ព្រះអង្គឡើយ ។ គ្រានោះ សក្កទេវរាជបានយាងទៅ ឃើញព្រះបាទធម្មាសោកហើយ បានហៅវិស្សកម្មទេវបុត្តមកថា នែអ្នកនិរទុក្ខ ព្រះរាជាព្រះបាទធម្មាសោក ព្រះ-

អង្គទ្រង់អារាធនាព្រះបរមធាតុទៅ ដូច្នេះ អ្នកចូរទៅកាន់ទីបរិវេណនោះ ហើយទម្លាយនូវរូបមនុស្សយន្តឈើនោះចេញ វិស្សុកម្មទេវបុត្តនោះ ក៏បាននិម្មិតខ្លួនជាក្មេងអ្នកស្រុកម្នាក់ មកកាន់ធ្នូក្នុងដៃ បានឋិតនៅចំពោះព្រះភក្ត្រព្រះរាជា ហើយបានទូលថា ខ្ញុំព្រះអង្គអាចនាំចេញបានមហារាជ ។ ព្រះរាជា ទ្រង់បានត្រាស់ថា អ្នកចូរនាំចេញចុះ ។ វិស្សុកម្មទេវបុត្តនោះ ក៏ចាប់កូនសរទាញតម្រង់បាញ់ខ្សែយន្ត ដែលខ្លួនចង់ទុកនោះឯង ធ្វើឲ្យគ្រប់ទីកន្លែងបែកជាបំណែកទាំងអស់ ។ គ្រានោះ ព្រះរាជាទ្រង់កាន់ត្រាដែលបោះភ្ជាប់នឹងសោ ដែលចងភ្ជាប់គ្នា ព្រះអង្គទតឃើញកែវមណី ដែលមានចារឹកអក្សរថា **ក្នុងកាលជាអនាគត ព្រះរាជាក្រខ្សត់ ចូរកាន់យកកែវមណីនេះហើយធ្វើសក្ការបូជា ព្រះបរមសារីរិកធាតុទាំងឡាយនេះចុះ** ! ព្រះបាទធម្មាសោក ទ្រង់មានព្រះទ័យពិរោធឡើងថា មិនគួរនិយាយមើលងាយ ព្រះរាជាដូចជាយើង ថាជាព្រះរាជាក្រខ្សត់ដូច្នេះសោះ ហើយទ្រង់បានបញ្ជាឲ្យបើកទ្វារ ព្រះអង្គក៏យាងចូលទៅខាងក្នុងព្រះស្តូបនោះ ប្រទីបដែលតម្រៀបទុក រហូតអស់កាល២១៨ឆ្នាំ ក៏មានសភាពឆេះនៅដដែល ផ្កាឈូក

ហាក់បីដូចជានាំមកបូជាក្នុងខណៈនោះ គ្រឿងលំអិត ហាក់បីដូចជាតម្កល់ថ្មីៗ ។ ព្រះបាទធម្មាសោក ទ្រង់កាន់យកផ្ទាំងមាសដែលមានចារឹកអក្សរដូច្នេះថា អនាគតេ យទា អសោកោ ណាម កុមារោ ឆត្តំ ឧស្សាបេត្វា អសោកោ ណាម ធម្មរាជា ភវិស្សតិ សោ ឥមា ធាតុយោ វិត្ថារិកា ករិស្សតិ ។ **ក្នុងអនាគតកាល គ្រាអសោកកុមារ ញ៉ាំងគេឲ្យលើកនូវស្វេតច្ឆត្រឡើង ហើយនឹងបានជាអសោកធម្មរាជា ព្រះរាជាអង្គនេះទ្រង់នឹងញ៉ាំងនូវព្រះបរមសារីរិកធាតុទាំងនេះ ឲ្យផ្សព្វផ្សាយទៅ ។** ព្រះរាជា បានអានចប់ហើយ ក៏កើតសេចក្ដីជ្រះថ្លា បានត្រាស់ថា បពិត្រលោកម្ចាស់ ព្រះថេរៈព្រះនាមថា មហាកស្សបត្ថេរ ជ្រាបនូវខ្ញុំព្រះអង្គហើយ ព្រះហស្តឆ្វេងកាន់ផ្ទាំងមាសព្រះហត្ថស្ដាំចារឹកអក្សរ ។

ព្រះរាជាបានអារាធនា នូវព្រះបរមសារីរិកធាតុ ដែលតម្កល់ទុកក្នុងព្រះស្តូបនោះទាំងអស់ (ដែលព្រះថេរៈអារាធនាមកពី៧នគរ វៀរតែព្រះបរមធាតុនៅរាមគ្រាម ដែលស្តេចនាគនាំទៅ) រួចហើយព្រះអង្គទ្រង់បញ្ជាឲ្យបិទទ្វារព្រះស្តូប ដែលតម្កល់នូវព្រះបរមសារីរិកធាតុ ដូចសភាពដើមវិញ ថែមទាំង

បានឲ្យប្រតិស្ឋាន **បាសាណចេតិយ** (ព្រះចេតិយថ្ម) ទុកពីខាងលើទៀតផង ។

ព្រះបាទធម្មាសោក ទ្រង់បានអារាធនា នូវព្រះបរមសារីរិកធាតុ ទៅបញ្ចុះក្នុងព្រះចេតិយ ដែលព្រះអង្គបានកសាងទុកទាំង៨៤០០០ព្រះចេតិយ នៅទូទៅក្នុងជម្ពូទ្វីប ។ ការផ្សព្វផ្សាយទៅ នៃព្រះបរមសារីរិកធាតុ របស់ព្រះសមណគោតមបរមគ្រូនៃយើង រហូតមកដល់ពេលនេះ មានដោយប្រការដូច្នេះឯង ៕

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតម សាវកា**
**យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។**

សតិរបស់ជនណា ទៅហើយក្នុង(គុណរបស់)ព្រះពុទ្ធជានិច្ច ទាំងយប់ទាំងថ្ងៃ ជនទាំងឡាយនោះ គឺជាសាវករបស់ព្រះគោតម រមែងមានការភ្ញាក់រលឹក ជាការភ្ញាក់ដ៏ប្រពៃសព្វកាល ។

# នាមពុទ្ធបរិស័ទដែលមានសទ្ធា
# បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

**( បោះពុម្ពលើកទី ១ ចំនួន ៨០០ ក្បាល )**

១. ឧបាសក **ភាំង ខ៉ែត** ឧបាសិកា **គាង គន្ធពិដោរ** ព្រមទាំងបុត្ត ១០០ $
២. ឧបាសិកា **នួន វណ្ណា** ព្រមទាំងកូនចៅ(U S A) ...............១០ $
៣. ឧបាសិកា **ម៉ូវ ស៊ីមាន** ព្រមទាំងស្វាមីនិងបុត្ត ..........៤០.០០០ ៛
៤. ឧបាសិកា **ម៉ូវ ស៊ីថា** ព្រមទាំងអ្នកម្ដាយ .................៤០.០០០ ៛
៥. ឧបាសិកា **លាង ហ៊ួន** ព្រមទាំងកូនចៅ ..................៤០.០០០ ៛
៦. ឧបាសិកា **លាន សុខទី** ព្រមទាំងកូនចៅ ........ចំនួន ១០០ ក្បាល
៧. ឧបាសិកា **លឹម ផេង** ព្រមទាំងបុត្ត ...............ចំនួន ១០០ ក្បាល
៨. ឧបាសិកា **ហ្លួវ សុខជា** ព្រមទាំងបុត្ត ..............ចំនួន ៩០ ក្បាល
៩. ឧបាសិកា **ហ៊ួរ សាំងអៀក** ព្រមទាំងកូនចៅ .......ចំនួន ៥០ ក្បាល
១០. ឧបាសិកា **ប៉ក់ សុផល** (អាចារ្យ ហួង) ...........ចំនួន ៥០ ក្បាល
១១. ឧបាសិកា **ឡុង សាវី** ព្រមទាំងស្វាមីនិងបុត្ត ...ចំនួន ១០ ក្បាល

**( បោះពុម្ពលើកទី ២ ចំនួន ២០០ ក្បាល )**

១. ឧបាសិកា **ហេង លាភ** ............................................... ១០ $
២. ឧបាសក **យន់ យូឈិត** ឧបាសិកា **គាង សុគន្ធា** ព្រមទាំងបុត្ត..១០ $
៣. ឧបាសក **ហេង ឡី** ឧបាសិកា **គាង រស្មីសោភា** ព្រមទាំងបុត្ត... ១០ $
៤. ឧបាសក **ស្រ៊ឹ សម្បត្តិ** ឧបាសិកា **គាង លក្ខិណា** ព្រមទាំងបុត្រី. ១០ $
៥. ឧបាសក **សោម សំណាង** ឧបាសិកា **គង់ រតនា** ព្រមទាំងបុត្ត... ៤០.០០០ ៛
៦. ឧបាសក **ពុំ ហេង** ឧបាសិកា **គ្រុយ ផល្លា** ព្រមទាំងបុត្ត ចំនួន៥០ក្បាល

៧. ឧបាសិកា **នួន សួន** .......................................ចំនួន ១០ ក្បាល

៨. ឧបាសក **អ៊ុច ពូន** ឧបាសិកា **សុខ សំអាន** ព្រមទាំងបុត្ត ចំនួន១០ក្បាល

៩. ឧបាសក **ពូន ប្រុស** ឧបាសិកា **សុខ អ៊ីម** ព្រមទាំងបុត្ត ចំនួន...១០ក្បាល

១០. ឧបាសក **ផល សារិ** ឧបាសិកា **ខែ៉ត សុភា** ...... ចំនួន ៥ ក្បាល

## អ្នកមានឧបការៈក្នុងការចេញធម្មទាន

១. លោកគ្រូធម្មាចារ្យ **ឈឿន តិរម្យ**

២. ឧបាសក **ដៀប លេន** ឧបាសិកា **គឹម រីយ៉ា**

៣. ឧបាសក **ភាំង ខែ៉ត** ឧបាសិកា **គាង គន្ធពិដោរ**

៤. ឧបាសក **ហេង ឡី** ឧបាសិកា **គាង ស្មើសោភា**

៥. ឧបាសក **ឡោ ហារី** ឧបាសិកា **គង់ លក្ខិណា**

៦. ប្អូន **ដួង ចន្ទ** (ហៅសាដង់) រួមនិងពុទ្ធបរិស័ទទូទៅទាំងអស់ ។

ទទតោ បុញ្ញំ បវឌ្ឍតិ

*បុណ្យរមែងចម្រើនដល់អ្នកឲ្យទាន ។*

សព្វទានំ ធម្មទានំ ជិនាតិ

*ធម្មទាន ឈ្នះអស់ទានទាំងពួង ។*